គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
Committee for Free and Fair Elections in Cambodia







# គោលនយោបាយយេនឌ័រ និងការផ្តល់អំណាចនយោបាយដល់ស្ត្រីនៅកម្ពុជា

# Gender Policy and Women Political Empowerment in Cambodia







ខែមីនា ឆ្នាំ២០១១

# មាតិកា

ទំព័រ

**១. បរិបទស្តីពីការផ្តល់អំណាចនយោបាយយេនឌ័រនៅកម្ពុជា........................................១**

**២. សេចក្តីផ្តើម និងអនុសាសន៍.....................................................................................៤**

គណបក្សនយោបាយ

ក្រសួងកិច្ចការនារី/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ/សង្គមស៊ីវិល

**៣. របាយការណ៍សង្ខេបសិក្ខាសាលា ស្តីពី "ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោល-
នយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់"..............៨**

**ឧបសម្ព័ន្ធទី១.............................................................................................................១៧**

គំរូនៃផែនការសកម្មភាពសម្រាប់សមភាពយេនឌ័រនៅក្នុងគណបក្សពលករនវ័វេស្សន៍

**ឧបសម្ព័ន្ធទី២.............................................................................................................២២**

សកម្មភាព និងលទ្ធផលនៃកម្មវិធីស្ត្រីអាចធ្វើបាន

**ឧបសម្ព័ន្ធទី៣.............................................................................................................២៤**

វត្តមានអ្នកចូលរួមសិក្ខាសាលា ស្តីពី " ការផ្តល់អំណាចនយោបាយដល់ស្ត្រី និង
គោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ "

**ឧបសម្ព័ន្ធទី៤.............................................................................................................២៥**

ការចុះ និងចាក់ផ្សាយរបស់ប្រពន្ធ័ផ្សព្វផ្សាយ

## ១. បរិបទស្តីពីការផ្តល់អំណាចនយោបាយយេនឌ័រនៅកម្ពុជា

នៅបរិបទកម្ពុជាការផ្តល់អំណាចនយោបាយយេនឌ័រ គឺនិយាយដល់ការពង្រឹង ការលើកស្ទួយ និងការការពារការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចចិត្តខាងនយោបាយ រួមទាំងការផ្តល់លទ្ធភាព និងឱកាសដល់ស្ត្រីដើម្បីទទួលបាន "**អំណាចនយោបាយ**" ដោយត្រូវខិតខំធ្វើឱ្យមានសមភាពរវាងបុរស និងស្ត្រីក្នុងអំណាចនយោបាយ និងការសម្រេចចិត្ត។

ក្រៅពីអតុល្យភាពនៃសិទ្ធិសេរីភាព និងអំណាចរដ្ឋ កម្ពុជាមានបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិរវាងបុរស និងស្ត្រី។ អ្នកនយោបាយកម្ពុជាភាគច្រើនគឺបុរស ឯស្ត្រីវិញមានឱកាសតិចតួចក្នុងការចូលរួមក្នុងឆាកនយោបាយ។ ផ្នែកខ្លះនៃបញ្ហានេះ កើតឡើងដោយសារទំនៀមទម្លាប់អភិរក្សនិយម និងវប្បធម៌ដែលត្រូវបានគេសន្មត់ និងផ្តល់តម្លៃស្ត្រីទាបជាងបុរសនៅគ្រប់វិស័យនៅក្នុងសង្គម។ ជាងនេះទៅទៀត ភាពក្រីក្រ អវិជ្ជា ការរើសអើង ខ្វះការលើកទឹកចិត្ត និងឱកាស និងអវត្តមាននូវគោលនយោបាយជាក់លាក់ក្នុងការលើកកម្ពស់ និងផ្តល់ឱកាសដល់ស្ត្រី គឺជាបច្ច័យដែលក្លាយជាឧបសគ្គសម្រាប់ស្ត្រីក្នុងការទទួលបាននូវសមភាព និងផលចំណេញពីការចូលរួមក្នុងវិស័យនយោបាយ និងកិច្ចការសង្គម។

ខាងក្រោមនេះ គឺជាការវិភាគអំពីស្ថានភាព និងលទ្ធភាពក្នុងការផ្តល់អំណាចនយោបាយយេនឌ័រក្នុងន័យធ្វើឱ្យមានសមភាពរវាងបុរស និងស្ត្រីចូលរួមក្នុងនយោបាយ ដោយឡែកការបោះឆ្នោត។

កម្ពុជាមិនទាន់មានសមភាពយេនឌ័រនៃការផ្តល់អំណាចខាងនយោបាយ ពិសេសភាពជាតំណាងអ្នកបោះឆ្នោតជាប់ឆ្នោត ថ្វីបើអ្នកចុះឈ្មោះបោះឆ្នោតជាស្ត្រីមាន៥៣%ក៏ដោយ គឺស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រមានចំនួនតែ**២២%** សម្រាប់អាណត្តិទី៤ និងស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួន**១៦,០៨%**សម្រាប់អាណត្តិទី២។ យោងតាមរបាយការណ៍ UNDP's Human Development Index ឆ្នាំ២០០៩ កម្ពុជាមានកម្រិតទាបនៃសមធម៌យេនឌ័រនៅក្នុងប្រទេសអាស៊ី ភាគច្រើន សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ**០,៥៨៨** និងកម្រិតសន្ទស្សន៍ការផ្តល់អំណាចយេនឌ័រមាន**០,៤២៧** ដែលកម្រិត នៅលេខ**៩១** ដែលធៀបលេខអន់បំផុត១០៩។ ទោះបីបានទទួលលទ្ធផលរីកចម្រើនខ្លះនៅក្នុងគោលនយោបាយលើកស្ទួយសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រគឺនៅតែប្រឈមច្រើន ហើយកំណែទម្រង់ និងការអនុវត្តន៍គោលនយោបាយនៅមានភាពទន់ខ្សោយនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំឱ្យមានភាពជឿនលឿនមួយទៀតដែលពីមុនពុំធ្លាប់មាន គឺការតែងតាំងអភិបាលរងរាជធានី ខេត្តជាស្ត្រីចំនួន**២៤រូប**គ្រប់រាជធានី ខេត្ត និងអភិបាលរងស្រុក/ខណ្ឌ ចំនួន **១៦៩រូប**ក្នុងចំណោម១៨៥ស្រុក/ខណ្ឌ និងមានការបោះឆ្នោតអសកលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្ត្រីជាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន **៣៨៨នាក់(១២%)** និងស្ត្រីជាមេភូមិចំនួន **៥៩៣នាក់ (៣,៧១%)** ប៉ុន្តែនៅមានកង្វះខាតការប្តេជ្ញាចិត្តពីតំណាងអ្នកបោះឆ្នោតនៅថ្នាក់ជាតិ និងរាជរដ្ឋាភិបាលក្នុងការបង្កើតឱ្យមានក្របខណ្ឌច្បាប់ គ្រប់គ្រាន់ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ តួលេខទាំងនេះបង្ហាញថា កម្ពុជានៅមានការប្រឈមក្នុងការអនុវត្តន៍របស់រាជរដ្ឋាភិបាលដើម្បីឱ្យ

សម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDG)ដែលកម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិ យ៉ាងតិច ៣០% និងថ្នាក់ឃុំ សង្កាត់ ២៥% ។

មានការស្រាវជ្រាវដាច់ដោយឡែកទាក់ទិនភាពសកម្មរបស់ស្ត្រីក្នុងកិច្ចការនយោបាយ( ការស្រាវជ្រាវស្តីពីការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ ខុមហ្វ្រែល ខែវិច្ឆិកា ឆ្នាំ២០០៩) បានរកឃើញថា ស្ត្រីចូលរួមដោយស្ម័គ្រចិត្តក្នុងសកម្មភាពនយោបាយតិចជាងបុរស (**បុរស២៥%**) មានតែ**១៤%** ក្នុងចំណោមស្ត្រី។ បន្ថែមបញ្ហាស្ត្រីក៏ជួបឧបសគ្គច្រើនក្នុងការបោះឆ្នោត។ មានអ្នកបោះឆ្នោតស្ត្រីប្រហែល **២២០ ០០០នាក់**បានចេញទៅបោះឆ្នោតប៉ុន្តែបានជួបឧបសគ្គដែលបណ្តាលឱ្យពួកគាត់ពុំអាចបោះឆ្នោតបាននៅថ្ងៃបោះឆ្នោតឆ្នាំ២០០៨ (យោងតាមរបាយ-ការណ៍ខុមហ្វ្រែលស្តីពី លទ្ធផលអង្កេតបញ្ជីបោះឆ្នោតឆ្នាំ២០០៩)។ ក្នុងនោះ ស្ត្រីជាជនពិការជួបឧបសគ្គខ្លាំងជាងគេ។ តាមលទ្ធផលការអង្កេតស្រាវជ្រាវរបស់អង្គការជនពិការកម្ពុជា ខុមហ្វ្រែល និងអង្គការជនពិការអន្តរជាតិ បារាំង (HIF) ស្តីពី *"ការចូលរួមរបស់ស្ត្រីពិការនៅក្នុងផ្នែកនយោបាយនៅកម្ពុជា "* នៅឆ្នាំ២០១០[(១)] បង្ហាញថាការចូលរួមរបស់ស្ត្រីពិការទាំងក្នុងដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតនៅមានកម្រិតទាប។ បើប្រៀបធៀបរវាងស្ត្រីពិការ និងស្ត្រីគ្មានពិការភាពក្នុងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៩ នៅក្នុងខេត្ត ក្រុងចំនួន៣ គឺខេត្តកំពង់ស្ពឺ កំពង់ចាម និងក្រុងភ្នំពេញ បង្ហាញឱ្យឃើញថា ស្ត្រីពិការចំនួនតែ **៥១,៣%**បានទៅចុះឈ្មោះបោះឆ្នោតខណៈដែលស្ត្រីគ្មានពិការភាពមានចំនួនដល់ទៅ **៧៦,៧%** ។ ស្ត្រីពិការបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨មានចំនួនតែ**៥៨,៨%** បើធៀបនឹងស្ត្រីគ្មានពិការភាពមានចំនួន **៩៤,៤%**។ មានចំណុចសំខាន់**ចំបង៣**ដែលជនពិការទាំងពីរភេទប្រឈមមុខ: *(១) ខ្វះព័ត៌មាន (២) គ្មានការផ្តល់ឱកាស និង (៣) ត្រូវបានគេផាត់ចេញពីសង្គម (រើសអើង)*។

ការលើកស្ទួយ និងការផ្តល់អំណាចនយោបាយដល់ស្ត្រីនេះ ក៏ត្រូវបានពិនិត្យផងដែរនៅក្នុងគណបក្សនយោបាយ ពិសេសគណបក្សនយោបាយជាប់ឆ្នោត។ ការសិក្សារបស់ខុមហ្វ្រែលនៅចុងឆ្នាំ២០១០រកឃើញថាគណបក្សសំខាន់៧ដែលមានអាសនៈនៅក្នុងសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ ចង់ឱ្យមានគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយដែលមានបំណងជំរុញឱ្យស្ត្រី និងបុរសបានចូលរួមក្នុងកិច្ចការនយោបាយស្មើគ្នា។ គណបក្សខ្លះបានលើកឡើងថា ការផ្តល់អំណាចនយោបាយខាងយេនឌ័រ (ជាពិសេសស្ត្រី) មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណបក្សខ្លួន ឬនៅក្នុងកម្មវិធីនយោបាយ។ ដោយឡែក គណបក្សកាន់អំណាច(គណបក្សប្រជាជនកម្ពុជា) បានការពារថា អ្វីជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការលើកស្ទួយយេនឌ័រ ឬ ស្ត្រីក៏ជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់គណបក្សខ្លួនដែរ។ ទោះជាយ៉ាងណាក៏ដោយ គណបក្សទាំងនេះពុំទាន់

---

(១) របាយការណ៍ស្រាវជ្រាវ ស្តីពី "ការចូលរួមរបស់ស្ត្រីពិការនៅក្នុងវិស័យនយោបាយនៅកម្ពុជា" ផ្សព្វផ្សាយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ (CDPO, COMFREL, HIF) នៅខេត្តកំពង់ស្ពឺ កំពង់ចាម និងក្រុងភ្នំពេញ

មានគោលនយោបាយ ឬផែនការសកម្មភាពជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់ទាក់ទិននឹងយេនឌ័រក្នុងកិច្ចការរបស់គណបក្សនៅឡើយដែរ។

មានការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជម្រុញឱ្យមានកូតាមិនផ្លូវការនៅក្នុងតំណែងរដ្ឋាភិបាល និងមានការអំពាវនាវ ណែនាំពីមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលរួមទាំងនាយករដ្ឋមន្ត្រីថ្មីៗនេះនៅក្នុងវេទិកាលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិនៅថ្ងៃទី០២-០៣ ខែវិច្ឆិកា ឆ្នាំ២០១០ សុំឱ្យគណបក្សនយោបាយទាំងអស់ដាក់បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើនៅក្នុងបញ្ជីឈរឈ្មោះគណបក្សរបស់ខ្លួន ដើម្បីឱ្យបេក្ខជនស្ត្រីបានជាប់ឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ និងឆ្នាំ២០១៣ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ មានប្រជាពលរដ្ឋ (ភាគច្រើនអ្នកមានសិទ្ធិបោះឆ្នោត) **៨៧%** បានគាំទ្រទៅលើការបង្កើតច្បាប់បំរុងអាសនៈសម្រាប់ស្ត្រីក្នុងការចូលរួមសកម្មភាពនយោបាយ ដូចជា ការឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬ សមាជិកសភា (ការសិក្សាស្តីពី "ការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ" របស់ខុមហ្វ្រែល ខែវិច្ឆិកា ឆ្នាំ២០០៩)។

រាជរដ្ឋាភិបាលបានជម្រុញការដាក់ស្ត្រីក្នុងស្ថាប័នរដ្ឋ តាមរយៈកំណត់កូតាយ៉ាងហោចណាស់មានស្ត្រីជាអនុប្រធាន ។ ការជម្រុញដោយបទបញ្ជាផ្ទាល់មាត់មានប្រសិទ្ធភាពខ្លះដែរ ជាក់ស្តែងកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១ លោកស្រី **អ៊ុន សុគន្ធា**ត្រូវបានតែងតាំងជាឧត្តមសេនីយ៍ផ្កាយ៣ និងជាមេបញ្ជាការរងនៃស្នងការនគរបាលជាតិ។ ប៉ុន្តែការផ្តល់កូតានេះពុំទាន់មានជាគោលនយោបាយ ឬ នីតិវិធីច្បាប់ផ្លូវការនោះទេ។ អាចថាវាមានការលំបាកចំពោះរាជរដ្ឋាភិបាលក្នុងការធ្វើនីតិវិធីច្បាប់ ឬគោលនយោបាយផ្លូវការ ព្រោះថាខ្វះមូលដ្ឋានច្បាប់គោលជាក់ស្តែងក្នុងការផ្តល់កូតាដល់បុរស និងស្ត្រីក្នុងតំណែងមន្ត្រីជាប់ឆ្នោត ឬមន្ត្រីចាត់តាំងនៃស្ថាប័នរដ្ឋ។

ក្នុងការប្រឈមនៃលទ្ធភាពក្នុងការបង្កើតច្បាប់ ឬគោលនយោបាយរបស់រដ្ឋដើម្បីជំរុញការផ្តល់អំណាចនយោបាយជាកូតាយេនឌ័រជាវិធានការពិសេសវិជ្ជមាន គណបក្សនីមួយៗអាចជាតួអង្គសំខាន់តាមរយៈការបង្កើតគោលនយោបាយ ឬ ផែនការសកម្មភាពជាក់ស្តែងក្នុងការផ្តល់អំណាចនយោបាយទៅតាមទស្សនៈយេនឌ័រ។ ព្រោះថាប្រព័ន្ធបោះឆ្នោតនៅកម្ពុជា គឺជាប្រព័ន្ធសមាមាត្រ គណបក្សនយោបាយ ឬអ្នកដឹកនាំគណបក្សជាអ្នកសម្រេចបេក្ខជន (បុរស និងស្ត្រី) ដើម្បីដាក់ក្នុងបញ្ជីឈរឈ្មោះរបស់គណបក្សសម្រាប់ការបោះឆ្នោត។ ច្បាប់ ឬគោលនយោ-បាយទាក់ទិននឹងកូតាយេនឌ័រនេះអាចមិនប្រឆាំងនឹងរដ្ឋធម្មនុញ្ញទេ ហើយក៏មិនមាននយ័រើសអើងដែរ។ វាជាវិធាន-ការពិសេសបណ្តោះអាសន្នក្នុងការធានាឱ្យស្មើគ្នារវាងស្ត្រី និងបុរសក្នុងការចូលរួមក្នុងវិស័យនយោបាយ និងកិច្ចការសាធារណៈ។ បញ្ញត្តិកូតាយេនឌ័រនេះគឺមានន័យថា ផ្តល់ឱកាសដូចគ្នាដល់ភេទទាំងស្ត្រី និងបុរសក្នុងករណីស្ថានភាពវិសមភាព។ គណបក្សក៏អាចរៀនសូត្រ និងដកពិសោធន៍ពីបណ្តាប្រទេសមួយចំនួននៅប្រទេសខ្លះបានរៀបចំគោលនយោបាយយេនឌ័រ ឬផែនការសកម្មភាពជាក់ស្តែងសម្រាប់សមភាពយេនឌ័រនៅក្នុងគណបក្សរបស់ពួកគេ។ ជាបទពិសោធ គណបក្សមួយនៅប្រទេសន័រវេស្សរ៍មានផែនការសកម្មភាពស្តីពី "*សមភាពយេនឌ័រ* " ដែលបានបង្ហាញពីការប្តេជ្ញាចិត្តជាវិជ្ជមានសមភាព ៥០%ស្ត្រី ៥០%បុរសក្នុងគ្រប់មុខតំណែងរបស់បក្ស។ នៅក្នុងផែនការសកម្មភាព

នៃគណបក្សមួយនេះ មានស្នើការរៀបចំបណ្ដាញ ឬចលនាស្ត្រីក្នុងបក្ស កម្មវិធីបណ្តុះបណ្តាលដែលជំរុញឱ្យមានសមភាពយេនឌ័រ និងបង្កើតសន្និសីទជាតិ សិក្ខាសាលា វេទិកាពាក់ព័ន្ធនឹងបញ្ហាស្ត្រី។ ជាការពិតនៅកម្ពុជាក៏មានការខិតខំរបស់គណបក្សកាន់អំណាច និងគណបក្សប្រឆាំងដែលបានបង្កើនចំនួនស្ត្រីក្នុងគណបក្ស និងជាមន្ត្រីជាប់ឆ្នោត ហើយបានបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់អ្នកនយោបាយ និងសកម្មជនស្ត្រីទាំងនោះ។ នៅតំបន់ដែលខុមហ្វ្រែលធ្វើសកម្មភាពពង្រឹងស្ត្រីចូលរួមនយោបាយ ឬការហ៊ឹកហ្វឺនស្ត្រីអាចធ្វើបាន និងការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត មានកើតចេញនៅបាតុភូតមួយថា សកម្មជន ឬមន្ត្រីនៅមូលដ្ឋានឃុំ សង្កាត់របស់គណបក្សប្រឆាំងបានចុះចូលជាមួយគណបក្សកាន់អំណាចមានមួយចំនួន។ មូលហេតុនៃការចុះចូលនេះមានការពន្យល់ផ្សេងៗដូចជា ស្ត្រីទាំងនោះមានការភ័យខ្លាច ឬគណបក្សប្រឆាំងទាំងនោះមិនសូវយកចិត្តទុកដាក់ដល់ស្ត្រីទាំងនោះ ឬការមានឥទ្ធិពលខ្លាំងនៃការទាក់ទាញទិញទឹកចិត្តរបស់គណបក្សកាន់អំណាច។

សំណួរជាច្រើនបានលើកឡើងថា តើស្ត្រីដែលបានអំណាចនយោបាយ ពិតជាបានចូលរួមជួយក្នុងការអភិវឌ្ឍន៍ជាពិសេសដោះស្រាយបញ្ហានានាទាក់ទិននឹងស្ត្រី និងកុមារមានប្រសិទ្ធភាពឬទេ? តើស្ត្រីដែលមានអំណាចហើយមានការលំបាកដែរឬទេក្នុងការអនុវត្តតួនាទី ភារកិច្ច? តើមានការលាលែងចេញពីតំណែងដែរឬយ៉ាងណា?

យោងតាមការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលឆ្នាំ២០១០ នៅតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ១០ស្រុក ឃុំចំនួន១០ក្នុងចំណោម៧៣ឃុំ ក្នុងខេត្តចំនួន៥ គឺ ខេត្តកំពង់ធំ កំពង់ចាម កំពង់ឆ្នាំង តាកែវ និងខេត្តព្រះវិហារ[២] បានរកឃើញថា ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហាស្ត្រី និងកុមារ ពិសេសអំពើហឹង្សាក្នុងគ្រួសារ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានជួយជម្រុញ និងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បង្កើតគណៈកម្មាធិទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មការផ្សេងទៀត រួមទាំងពង្រឹងឱ្យមានការងារស្ត្រីដែលមានស្ត្រីម្នាក់ជាជនបង្គោលទទួលបន្ទុកការងារស្ត្រី និងកុមារនៅឃុំ សង្កាត់ដែលបានធ្វើសកម្មភាពជួយទប់ស្កាត់ការរំលោភ ហឹង្សាលើស្ត្រី និងដោះស្រាយបញ្ហាស្ត្រី និងកុមារ។ ការសិក្សាបានរកឃើញផងដែរ បើក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សារួមទាំងស្ត្រី និងបុរសនោះ បញ្ហាស្ត្រី និងកុមារបានយកចិត្តទុកដាក់ជាងក្រុមប្រឹក្សាដែលមានសុទ្ធតែបុរស។

ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវបានរកឃើញផងដែរ ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ ១៨,២% ត្រូវបានទទួលការរើសអើង និងរិះគន់ពីបុរសក្នុងពេលបំពេញការងារដែលយល់ថា ស្ត្រីធ្វើការដូចមិនឃើញមានប្រសិទ្ធភាពអ្វីផង។ ជាធម្មតាផ្នត់គំនិតសង្គមខ្មែររួមទាំងបុរសដែរ តែងតែឱ្យតម្លៃស្ត្រីទាបជាងបុរសទោះបីមានស្ត្រីខ្លះមានសមត្ថភាព ឆ្លាតវាងវៃជាងបុរសខ្លះក៏ដោយ ការយល់ឃើញបែបនេះគឺជាផ្នត់គំនិតដ៏ខុសឆ្គង។ ការស្រាវជ្រាវបង្ហាញទៀតថា ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ១៨,២% មិនបានទទួលភារកិច្ចសោះពីប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួនដើម្បីបំពេញការងារ។ វាជាការខុសឆ្គង ការរើសអើងតួនាទីដែលមិនស្របតាមច្បាប់ស្តីពី *ការគ្រប់គ្រង*

---

(២) របាយការណ៍ស្រាវជ្រាវខុមហ្វ្រែល ស្តីពី "ស្ថានភាពរបស់ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅមូលដ្ឋាន" ឆ្នាំ២០១០

*រដ្ឋបាលឃុំ សង្កាត់* បានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។ លទ្ធផលស្រាវជ្រាវបញ្ជាក់ទៀតថា ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់១១នាក់ មាន១នាក់ឆ្លើយថាមានស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់លាលែងពីតំណែងចំនួន១នាក់ ព្រោះគាត់ឈឺ។ ការពិតចំនួនស្ត្រីជាប់ឆ្នោតគឺមានតិច ប៉ុន្តែអ្វីជាការព្រួយបារម្ភ នៅពេលស្ត្រីជាប់ឆ្នោតណាមួយលាលែងពីតំណែងបែរជាត្រូវជំនួសតំណែងដោយបុរស។ នៅមានការប្រឈមអំពីរបៀប ឬវិធីដែលអាចរក្សាចំនួនស្ត្រីជាប់ឆ្នោតបើមានករណីដូចខាងលើដែលលាលែង។ ដូច្នេះ ដើម្បីបង្កើនចំនួនស្ត្រី គឺត្រូវធ្វើតាមរយៈការរក្សា ការពារចំនួនស្ត្រីជាប់ឆ្នោត និងផ្តល់ឱកាសដល់ស្ត្រីជំនួសបុរសជាប់ឆ្នោតដែលបានលាលែងពីតំណែង។ មានន័យថា បើករណីមានស្ត្រីជាប់ឆ្នោតណាមួយត្រូវបានលាលែងពីតំណែងគួរតែមានស្ត្រីផ្សេងមកជំនួស ផ្ទុយមកវិញបើករណីបុរសត្រូវបានលាលែងពីតំណែងគួរតែយកស្ត្រីមកជំនួសផងដែរ។

មានតែ ៤៥.៩០% ជឿថា**មាន**សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍បញ្ហាសង្គមកិច្ចនៅមូលដ្ឋាន ព្រោះស្ត្រីបានចងជាបណ្តាញ និងរចនាសម្ព័ន្ធសំរាប់ការងារស្ត្រីមានជាប្រចាំ ដូចជា បញ្ហាសុខភាព ការបន្តពូជ អំពើហឹង្សាក្នុងគ្រួសារ។ ឃុំ សង្កាត់ដែលមានស្ត្រីច្រើនជាក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើឱ្យការងារដំណើរការបានល្អ ស្ត្រីងាយពិភាក្សាការងារជាមួយបុរស ការដោះស្រាយបញ្ហាបានរហ័ស។ ៤០% ឆ្លើយថា ការអភិវឌ្ឍត្រូវតែមានភេទទាំងពីរចូលរួម បើមានមួយអត់មួយក៏ពិបាកធ្វើការងារដែរ ស្ត្រីដឹងពីទុក្ខធុរៈស្ត្រីដូចគ្នា។

ការសិក្សារបស់ខុមហ្វ្រែលនេះក៏បានបញ្ជាក់បន្ថែមថា សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្រុមគោលដៅរបស់ខុមហ្វ្រែលចង់ឱ្យមានគោលនយោបាយយេនឌ័រសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងកិច្ចការងារក្នុងការធានាឱ្យស្មើភាពគ្នារវាងបុរស-ស្ត្រីរួមទាំងសិទ្ធិ ឱកាសក្នុងការបង្កើនសមត្ថភាព និងការសម្រេចចិត្តការធ្វើផែនការ និងថវិកា។ គោលនយោបាយនេះអាចរៀបរាប់បន្ថែមអំពី **Gender Sensitive** នៅកន្លែងធ្វើការ។

លទ្ធផលសិក្ខាសាលាថ្នាក់ជាតិ ស្តីពី "ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ " សហការរៀបចំដោយខុមហ្វ្រែល គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គ.ស.ន/CPWP) និងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា(GAD/C) នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០បានបង្ហាញថា គណបក្សនយោបាយទាំង៥រួមទាំងតំណាងមកពីនាយកដ្ឋានគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងអង្គការក្រៅរដ្ឋាភិបាលទទួលស្គាល់ និងគាំទ្រការផ្តល់សិទ្ធិអំណាចនយោបាយដល់ស្ត្រី និងការបង្កើតឱ្យមាន "***ផែនការសកម្មភាព ឬគោលនយោបាយយេនឌ័រនៅក្នុងគណបក្ស នយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់*** " ប្រយោជន៍លើកស្ទួយសមភាពយេនឌ័រក្នុងកិច្ចការនយោបាយ និងសង្គមពិសេសលើកទឹកចិត្ត និងផ្តល់អំណាចនយោបាយដល់ស្ត្រីក្នុងការចូលរួមលើគ្រប់វិស័យ។ *(មានរបាយការណ៍លំអិតនៅផ្នែកទី៣នៃសៀវភៅនេះ)*

ជាសរុប បទបញ្ជា ឬអនុសាសន៍ ការប្តេជ្ញាចិត្ត និងការគាំទ្រផ្ទាល់មាត់របស់ថ្នាក់ដឹកនាំរដ្ឋាភិបាល និងគណបក្សនយោបាយមានតម្លៃ និងពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់ពង្រឹងការចូលរួមដោយស្មើភាពរវាង

ស្ត្រី និងបុរសនៅក្នុងនយោបាយ និងការបោះឆ្នោត ដោយឡែកការងារក៏រិតសម្រេចចិត្ត។ ទោះជាយ៉ាងនេះក៏ដោយ ការមានច្បាប់គោល គោលនយោបាយ ឬនីតិវិធីផ្លូវការទាក់ទិននឹងការផ្តល់អំណាចនយោបាយតាមរយៈកូតាយេនឌ័រ (បុរស និងស្ត្រីស្មើគ្នា) និងការធ្វើសកម្មភាព និងអនុវត្តគោលនយោបាយ និងច្បាប់ជាគន្លឹះសំខាន់ដើម្បីឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ដែលពិតជាមានប្រយោជន៍លើកទឹកចិត្តក្នុងការផ្តល់ឱកាសទូលាយដល់ការចូលរួមរបស់ស្ត្រី ឬបុរសស្មើគ្នាក្នុងវិស័យនយោបាយ និងកិច្ចការសង្គម។

## ២. សេចក្តីផ្តើម និងអនុសាសន៍

របាយការណ៍នេះ គឺរៀបរាប់អនុសាសន៍ និងរបាយការណ៍ ស្តីពីការផ្តល់អំណាចនយោបាយដល់ស្ត្រី និង គោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរៀបចំដោយ **COMFREL, CPWP** និង**GAD/C** នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ហើយក៏មានព័ត៌មានបន្ថែមនៅឧបសម្ពន្ធ ដូចជា គំរូនៃផែនការសកម្មភាពសម្រាប់សមភាពយេនឌ័ររបស់គណបក្សពលករន័រវេស្សន៍។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវរបស់ខុមហ្វ្រែលអំពី "ស្ថានភាពស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅមូលដ្ឋាន" និងការស្រាវជ្រាវអំពី "គោលនយោបាយយេនឌ័ររបស់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់" ខុមហ្វ្រែលបានរកឃើញនូវ**អនុសាសន៍**ជាគន្លឹះក្នុងការផ្តល់អំណាចនយោបាយដល់ស្ត្រី និងធ្វើឱ្យមានសមភាពយេនឌ័រនៅកម្ពុជាមានដូចតទៅ ÷

**<u>គណបក្សនយោបាយ</u>**

១- គួរតែ*បង្កើតផែនការសកម្មភាព ឬគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ* ដើម្បីឱ្យសមាជិកគណបក្សទាំងពីរភេទ ពិសេសសមាជិកជាស្ត្រីមានឱកាស និងលទ្ធភាពចូលរួមក្នុងវិស័យនយោបាយ។ គោលការណ៍សំខាន់ៗសម្រាប់ផែនការសកម្មភាព និងគោលនយោបាយយេនឌ័រនេះមានដូចខាងក្រោម ÷

(ក) ត្រូវ*អនុវត្តវិធានការសមធម៌*ដោយផ្តល់ឱកាសឱ្យស្ត្រីចូលរួមសកម្ម និងបង្ហាញនូវសក្តានុពលរបស់ខ្លួនក្នុងកិច្ចការនយោបាយ និងសង្គមជាជាងគិតតែអំពីសមត្ថភាពតែមួយមុខដែលជាឧបសគ្គដល់ស្ត្រីក្នុងការចូលរួម។

(ខ) សមាជិកគណបក្សនយោបាយទាំងពីរភេទ ត្រូវបាន*ទទួលការបណ្តុះបណ្តាល*យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ដើម្បីបង្កើនសមត្ថភាព និងភាពជឿជាក់ដែលជាកត្តាសំខាន់ឱ្យមានសកម្មភាពរស់រវើកក្នុងនយោបាយ និងទទួលមុខតំណែងជាអ្នកដឹកនាំ។

(គ) *បង្កើនចំនួនស្ត្រី ដើម្បីឈរឈ្មោះបោះឆ្នោត និងត្រូវដាក់បេក្ខជនស្ត្រីនៅលេខរៀងទី១ ឬក៏ ពីលេខរៀងទី១ ដល់ ទី៣ យ៉ាងហោចបាន ៣០%* នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់ខ្លួន *ឬឈរឈ្មោះឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរស*។

*(ឃ) បញ្ហានយោបាយរបស់ស្ត្រី និងសកម្មភាពស្ត្រីដែលជាសមាជិកគណបក្ស* ត្រូវតែជារបៀបវារៈនៃរាល់កិច្ចប្រជុំរបស់គណបក្សនយោបាយ ។

(ង) ត្រូវមានការ*ត្រួតពិនិត្យលើកម្មវិធីសម្រាប់ស្ត្រីនៅក្នុងគណបក្ស និងការណែនាំបន្ថែមទៀត*ដោយយកស្ត្រីដែលមានបទពិសោធនៅក្នុងគណបក្សដែលមានភាពសកម្មគឺជា*ម៉ូដែលគំរូ* ឬជាអ្នកណែនាំដើម្បីលើកទឹកចិត្ត និងចែករំលែកបទពិសោធ ។

(ច) ត្រូវបកស្រាយលើសមភាពយេនឌ័រនៅក្នុង*របាយការណ៍ប្រចាំឆ្នាំ*របស់ខ្លួន

(ឆ) បង្កើត*សន្និសីទជាតិ សិក្ខាសាលា វេទិកាពិភាក្សា*ពាក់ពន្ធ័នឹង*បញ្ហាស្ត្រី*

(ជ) ស្ត្រីជាថ្នាក់ដឹកនាំគួរមានក្នុងរចនាសម្ព័ន្ធគណបក្សតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន

២- គួរទទួលស្គាល់ថា *ចលនាស្ត្រីបក្សគឺជាកំលាំងចលករមួយដ៏សំខាន់*និងត្រូវបានយកចិត្តទុកដាក់ខ្ពស់

៣- *គួរមានថវិកាដោយឡែក*សម្រាប់សកម្មភាពការងាររបស់ចលនាស្ត្រី

៤- គួរ*ផ្តល់ថវិកាសម្រាប់បេក្ខជនស្ត្រី*ប្រើប្រាស់ក្នុងពេលឃោសនាបោះឆ្នោត

៥- *រក្សា ការពារចំនួនស្ត្រីជាប់ឆ្នោត និងផ្តល់ឱកាសដល់ស្ត្រីជំនួសបុរសជាប់ឆ្នោតដែលបានលាលែងពីតំណែង*។ បើករណីមានស្ត្រីជាប់ឆ្នោតណាមួយត្រូវបានលាលែងពីតំណែង គួរតែមានស្ត្រីផ្សេងមកជំនួស ផ្ទុយមកវិញបើករណីបុរសត្រូវបានលាលែងពីតំណែងគួរតែយកស្ត្រីមកជំនួសផងដែរ ។ ធ្វើបែបនេះ ទើបអាច*រក្សាចំនួនស្ត្រីជាប់ឆ្នោតឱ្យនៅនឹង និងអាចបង្កើនចំនួនស្ត្រី*នៅថ្នាក់សម្រេចចិត្តកាន់តែច្រើន ។

**ក្រសួងកិច្ចការនារី/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ/សង្គមស៊ីវិល**

៦- ក្រសួងកិច្ចការនារី ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល*ជួយបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ជាស្ត្រី* ស្តីពី ភាពជាអ្នកដឹកនាំ និងជំនាញផ្សេងៗ ដើម្បីចាត់ចែងឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការដោះ-ស្រាយបញ្ហា និងរបៀបដោះស្រាយទំនាស់នៅមូលដ្ឋាន ។

៧- ទាំងរដ្ឋាភិបាល ទាំងអង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធនានា ត្រូវតែ*ផ្សព្វផ្សាយនៅរៀងរាល់ការប្រជុំថ្នាក់ជាតិ និងមូលដ្ឋាន* និង*បន្តអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋប្រុស-ស្រីឱ្យបានយល់ដឹង និងបញ្ចុះបញ្ចូលឱ្យមានការផ្លាស់ប្តូរឥរិយាបថ*ក្នុងការទទួលយក អំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត អំពីសក្តានុពលរបស់ស្ត្រី អំពីភាពជាដៃគូដ៏សំខាន់របស់ស្ត្រី និងបុរសក្នុងការចូលរួមដឹកនាំ និងអភិវឌ្ឍន៍ប្រទេសជាតិ តាមមធ្យោបាយដូចជា ជួបផ្ទាល់តាមភូមិ-ផ្ទះ វិទ្យុ ទូរទស្សន៍ ពិសេសក្រសួងព័ត៌មាន និងស្ថាបន័ពាក់ពន្ធ័ ត្រូវ*ជួយសម្រួល*ក្នុងការចាក់ផ្សាយស្ប៉ុតអប់រំខ្លី ឬកិច្ចពិភាក្សាតុមូលតាមរយៈ វិទ្យុ និងទូរទស្សន៍ជាតិ ។

៨- ក្រុមប្រឹក្សាឃុំ សង្កាត់គួរ*តែបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃលើការងារ* និងស្ថានភាពការងាររបស់ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ត្រូវតែ*ពង្រឹងការអនុវត្តច្បាប់* ស្តីពី "*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* " ជាបន្ទាន់ដើម្បី*ផ្តល់សិទ្ធិអំណាច តួនាទី ភារកិច្ចពេញលេញដល់សមាជិកា*ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រយោជន៍ធានាដល់ការចូលរួមរបស់ស្ត្រីនៅថ្នាក់សម្រេចចិត្តនៅមូលដ្ឋាន។

១០- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃសហការជាមួយក្រសួងកិច្ចការនារីនិងស្ថាប័នពាក់ព័ន្ធទាំងអស់*បង្កើតគំរូនៃគោលនយោបាយយេនឌ័រសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់* ។ ហើយក្រសួងមហាផ្ទៃលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ពិនិត្យ រៀបចំ និងអនុមត៌គោលនយោបាយនេះ។

## ៣. របាយការណ៍សង្ខេបសិក្ខាសាលា ស្តីពី "ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់"

គណៈកម្មាធិការខុមហ្វ្រែលបានរៀបចំសិក្ខាសាលាស្តីពី " *ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ/សង្កាត់* "ដោយរួមសហការរៀបចំជាមួយCPWP និងអង្គការGAD/C នៅ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ។ នៅក្នុងសិក្ខាសាលានេះមានការអញ្ជើញ ចូលរួមពីតំណាងគណបក្សនយោបាយចំនួន៥ (គណបក្សប្រជាជនកម្ពុជា គណបក្សសម-រង្ស៊ី គណបក្សជាតិនិយម គណបក្សសិទ្ធិមនុស្ស និងគណបក្សហ៊្វុនស៊ិនប៉ិច) តំណាងក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បណ្តាញស្ត្រីនៅមូលដ្ឋាន សមាជិករដ្ឋាភិបាល ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាឃុំ-សង្កាត់ សម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកសារព័ត៌មានដូចជា ទូរទស្សន៍ វិទ្យុ និងកាសែត សរុបចំនួន **៩៨នាក់** ក្នុងនោះមានស្ត្រីចំនួន**៥៩នាក់**។

**លោក គល់ បញ្ញា** នាយកប្រតិបត្តិខុមហ្វ្រែល បានបង្ហាញពីទស្សនៈវិស័យទៅលើការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដោយផ្តោតលើចំណុច**សំខាន់ពីរ:***(១) ពិនិត្យមើលការផ្តល់អំណាចដល់ស្ត្រីតាមរយៈទស្សនៈយេនឌ័រក្នុងការធ្វើក្របខ័ណ្ឌច្បាប់ និងគោលនយោបាយផ្លូវការរបស់រដ្ឋដើម្បីបង្កើនចំនួនបុរស ឬស្ត្រីជាតំណាងជាប់ឆ្នោត។ (២)លទ្ធភាពនៃការរៀបចំធ្វើផែនការសកម្មភាព ឬគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់* ។

ជាទ្រឹស្តីការផ្តល់អំណាចនយោបាយយេនឌ័រ គឺនិយាយដល់ការពង្រឹង ការលើកស្ទួយ និងការការពារការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចចិត្តខាងនយោបាយ រួមទាំងការផ្តល់លទ្ធភាព និងឱកាសដល់ស្ត្រី ឬបុរស ដើម្បីទទួលបាន "អំណាចនយោបាយ" ដោយត្រូវខិតខំធ្វើឱ្យមានសមភាពរវាងបុរស និងស្ត្រីក្នុងអំណាចនយោបាយ និងការសម្រេចចិត្ត។

នៅកម្ពុជាមានបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិរវាងបុរស និងស្ត្រី និងមិនទាន់មានសមភាពយេនឌ័រនៃការផ្តល់អំណាចខាងនយោបាយពិសេសភាពជាតំណាងអ្នកបោះឆ្នោត។ អ្នកនយោបាយកម្ពុជាភាគច្រើនគឺ បុរស ឯស្ត្រីវិញមានឱកាសតិចតួចក្នុងការចូលរួមក្នុងឆាកនយោបាយ។ ម្យ៉ាងទៀតនៅមានការប្រឈមក្នុងការអនុវត្តន៍របស់

រាជរដ្ឋាភិបាល ដើម្បីឱ្យសម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDG)ដែលកម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិយ៉ាងតិច ៣០% និងថ្នាក់ឃុំ សង្កាត់ ២៥%។ ដូចនេះ ការផ្តល់អំណាចនយោបាយយេនឌ័រនៅកម្ពុជាគឺ និយាយដល់ការផ្តល់ឱកាសដល់ស្ត្រី ដើម្បីទទួលបានអំណាចនយោបាយ។ រដ្ឋាភិបាលអាចពិនិត្យលទ្ធភាពក្នុងការបង្កើតក្របខណ្ឌច្បាប់ ឬគោលនយោបាយជាផ្លូវការដោយផ្តល់កូតាដល់បុរស ឬស្ត្រីជាតំណាងជាប់ឆ្នោតអាចទៅដល់ចំនួនដែលកម្ពុជាបានកំណត់នៅក្នុង CMDG។

ក្រៅពីតួនាទីរបស់រដ្ឋាភិបាល គណបក្សនយោបាយគឺជាតួអង្គសំខាន់ដែលជម្រុញឱ្យមានការរីកចម្រើនការផ្តល់អំណាចយេនឌ័រ ពិសេសការផ្តល់អំណាចនយោបាយដល់ស្ត្រី។ ព្រោះថា ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា គឺជាប្រព័ន្ធសមាមាត្រ គណបក្សនយោបាយ ឬអ្នកដឹកនាំគណបក្សជាអ្នកសម្រេចបេក្ខជន (បុរស និងស្ត្រី) ដើម្បីដាក់ក្នុងបញ្ជីឈ្មោះរបស់គណបក្សសម្រាប់ការបោះឆ្នោត។ ការសិក្សារបស់ខុមហ្វ្រែលរកឃើញថា គណបក្សសំខាន់ៗមានអាសនៈនៅសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ ចង់ឱ្យមានគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ ដែលមានបំណងជំរុញឱ្យស្ត្រី និងបុរសបានចូលរួមក្នុងកិច្ចការនយោបាយស្មើគ្នា។ គណបក្សខ្លះបានលើកឡើងថា ការផ្តល់អំណាចនយោបាយខាងយេនឌ័រ (ជាពិសេស ស្ត្រី) មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណបក្សខ្លួន ឬនៅក្នុងកម្មវិធីនយោបាយ។ ដោយឡែកគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) បានការពារថា អ្វីជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ស្តីពី ការលើកស្ទួយយេនឌ័រ ឬស្ត្រីក៏ជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់គណបក្សខ្លួនដែរ។ ទោះជាយ៉ាងណាក៏ដោយ គណបក្សទាំងនេះពុំទាន់មានគោលនយោបាយ ឬផែនការសកម្មភាពជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់ទាក់ទិននឹងយេនឌ័រក្នុងកិច្ចការរបស់គណបក្សនៅឡើយដែរ។ ជាបទពិសោធគណបក្សមួយនៅប្រទេសន័រវេស្សរ៍មានផែនការសកម្មភាពស្តីពី "សមភាពយេនឌ័រ" ដែលបានបង្ហាញពីការប្តេជ្ញាចិត្តជាវិជ្ជមាន សមភាព៥០%ស្ត្រី ៥០%បុរសក្នុងគ្រប់មុខតំណែងរបស់បក្ស។ នៅក្នុងផែនការសកម្មភាពមានស្នើការរៀបចំបណ្តាញ ឬចលនាស្ត្រីក្នុងបក្ស កម្មវិធីបណ្តុះបណ្តាលដែលជំរុញឱ្យមានសមភាពយេនឌ័រ និងបង្កើតសន្និសីទជាតិ សិក្ខាសាលា វេទិកាពាក់ពន្ធ័នឹងបញ្ហាស្ត្រី។

ការសិក្សារបស់ខុមហ្វ្រែលឆ្នាំ២០១០ក៏បានរកឃើញផងដែរថា សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្រុមគោលដៅរបស់ខុមហ្វ្រែលចង់ឱ្យមានគោលនយោបាយយេនឌ័រសម្រាប់ឃុំ សង្កាត់ ដើម្បីពង្រឹងកិច្ចការងារក្នុងការធានាឱ្យស្មើភាពគ្នារវាងបុរស ស្ត្រីរួមទាំងសិទ្ធិ ឱកាសក្នុងការបង្កើនសមត្ថភាព និងការសម្រេចចិត្ត។ គោលនយោបាយនេះអាចរៀបរាប់បន្ថែមអំពី **Gender Sensitive** នៅកន្លែងការងារ។

ជាសរុប សិក្ខាសាលាយើង គួរតែពិភាក្សាអំពីលទ្ធភាពក្នុងការបង្កើតគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យស្ត្រី និងបុរសមានលទ្ធភាព ឱកាសចូលរួមសកម្មក្នុងកិច្ចការនយោបាយ និងកិច្ចការសាធារណៈ។

**លោក សួរ សុខខេង** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋភាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និង**លោក ខោល យុទ្ធលី** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានសំដែងការគាំទ្រការបង្កើតឱ្យមាន

គោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ វាពិតជាមានសារៈសំខាន់ណាស់ ជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការបង្កើនសមភាព យេនឌ័រសម្រាប់សមាជិកក្រុមប្រឹក្សា និងគណបក្សនយោបាយ ។

លោកបានបញ្ជាក់ថា កម្មវិធីជាតិរយៈពេល១០ឆ្នាំ(២០១០-២០១៩) សម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិ គឺជាការខិតខំប្រឹងប្រែងក្នុងការដាក់បញ្ចូលសមាមាត្រ និងតួនាទីស្ត្រី ជាពិសេសតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅក្នុងគ្រប់ផ្នែកនៃអភិបាលកិច្ច និងការធ្វើឱ្យស្ត្រីទទួលបានសេវាផ្សេងៗ។ កម្មវិធីជាតិបានផ្តល់នូវចំណុចចាប់ផ្តើម និងកាលានុវត្តភាពដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទាំង៥សំដៅឱកាសសម្រាប់ស្ត្រី និងធានាថាសេវាទាំងអស់ដែលជាតម្រូវការរបស់ស្ត្រីត្រូវបានឆ្លើយតប។ ដូច្នេះ ក្នុងការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបង្កើតឱ្យមានគោលនយោបាយយេនឌ័រសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺដើម្បីជួយពន្លឿនការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីចិត្តនៅគ្រប់កំរិត ធ្វើឱ្យស្ត្រីមានភាពក្លាហាន ឱ្យស្ត្រីមានឱកាសចូលរួមដោយសកម្ម និងបង្ហាញពីសក្តានុពលរបស់ខ្លួនក្នុងកិច្ចការនយោបាយ និងអភិវឌ្ឍន៍សង្គម ព្រមទាំងផ្តល់ឱកាសដល់បុរស-ស្ត្រីបានចូលរួមស្មើភាព។

**ឯកឧត្តម ស្វាន ទៀត** អនុប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និងជាតំណាងគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាមានគោលនយោបាយគ្រប់ជ្រុងជ្រោយហើយ បច្ចុប្បន្នកំពុងសកម្មក្នុងការផ្តល់ឱកាសដល់ស្ត្រីដើម្បីទទួលបានតួនាទីសមស្របក្នុងការដឹកនាំប្រទេស ទាំងស្ថាប័ននយោបាយ និងរដ្ឋ។ គណបក្សប្រជាជនបានឯកភាពលើទស្សនៈនៃការផ្តល់អំណាចនយោបាយដល់ស្ត្រី គឺ អនុលោមតាមស្មារតីរដ្ឋធម្មនុញ្ញមាត្រា ៣៥ បានចែងថា " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ... " ឯកឧត្តមមានយោបល់បន្ថែមទៀតថា ការលើកឡើងនូវគោលនយោបាយយេនឌ័រ គោលបំណងគណបក្សប្រជាជនកម្ពុជា គឺ

- លើកទឹកចិត្តឱ្យស្ត្រីបន្តប្រពៃណីល្អចូលរួមចំណែកក្នុងវិស័យការពារមាតុភូមិ កសាងជាតិ និងអភិវឌ្ឍន៍ជីវភាពគ្រួសារ។
- លើកទឹកចិត្តស្ត្រីក្នុងការសម្រេចចិត្តខាងនយោបាយតាមរយៈចូលរួម និងគាំទ្រនយោបាយក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺគណបក្សរៀបចំបេក្ខនារីឈរឈ្មោះសម្រាប់ការបោះឆ្នោត ធ្វើយ៉ាងណាឱ្យមានស្ត្រីជាប់ជាតំណាងនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ និងសភា។ ទោះជាយ៉ាងនេះក៏ដោយ ស្ត្រីកុំរង់ចាំការផ្តល់អំណាចដោយឯកឯង ស្ត្រីត្រូវតស៊ូមតិពុះពារគ្រប់កិច្ចការ កសាងអំណាចដោយស្ត្រីខ្លួនឯង ស្ត្រី៥២%នៃប្រជាពលរដ្ឋទូទៅស្ត្រីត្រូវតែមានតំណាងក្នុងស្ថាប័ននយោបាយ និងស្ថាប័នរដ្ឋ។
- បន្សាំផ្នែកស្មារតីរបស់បុរសចំពោះកិច្ចការដែលស្ត្រីបាន និងត្រូវបំពេញ ដោយត្រូវទទួលស្គាល់សមត្ថភាពរបស់ស្ត្រី និងគាំទ្របេក្ខជនស្ត្រីក្នុងកិច្ចការនយោបាយ និងកិច្ចការរដ្ឋ។

**លោកជំទាវ ម៉ែន មុនីរតនា** អនុប្រធានចលនាស្ត្រី និងជាអតីតតំណាងរាស្ត្រខេត្តព្រៃវែងនៃគណបក្សសម-រង្ស៊ីបានធ្វើបទបង្ហាញថា គណបក្សសម-រង្ស៊ី មានទិសដៅយ៉ាងច្បាស់លាស់ក្នុងការផ្តល់អំណាចនយោបាយដល់ស្ត្រី និងបង្កើនស្ត្រីឱ្យមានចំនួនច្រើនក្នុងវិស័យនយោបាយក៏ដូចជាអប់រំឱ្យស្ត្រីពង្រឹងសមត្ថភាពខ្លួនឯងក្នុងវិស័យផ្សេង។ គោលនយោបាយ និងផែនការសកម្មភាពយេនឌ័រសំរាប់គណបក្សសមរង្ស៊ីមានដូចជា:

- ការពារ និង លើកតំកើងពិតប្រាកដនូវសិទ្ធិសេរីភាពរបស់ស្ត្រីខ្មែរ
- បំផុស និងបណ្តុះបណ្តាលស្ត្រីខ្មែរឱ្យមានសេចក្តីក្លាហានក្នុងការបញ្ចេញមតិ ឬតវ៉ាដើម្បីកសាងលទ្ធិប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ប្រទេស។
- ជំរុញ និងទាមទារឱ្យមានការកំចាត់អំពើពាលាអាវ៉ាសែ ការជួញដូរមនុស្ស អំពើហឹង្សាក្នុងគ្រួសារ និងទាមទារឱ្យរដ្ឋាភិបាល ក៏ដូចជាអង្គការសង្គមស៊ីវិលឱ្យយកចិត្តទុកដាក់ចំពោះស្ត្រី។
- ផ្តល់ការលើកទឹកចិត្តដល់ស្ត្រីដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរភាពជាអ្នកដឹកនាំ
- ផ្តល់អំណាចដល់ស្ត្រីដើម្បីជំរុញឱ្យស្ត្រីមានការងារធ្វើ មានការអប់រំ និងមានសេវាសុខភាព ព្រមទាំងពង្រឹងនូវសមត្ថភាពស្ត្រីសម្រាប់ជាទុនដោះស្រាយបញ្ហា។
- ផ្តល់លទ្ធភាពដល់ស្ត្រីក្នុងការឈរឈ្មោះ និងស្វែងរកសន្លឹកឆ្នោតដោយជួយជាថវិកា និងមធ្យោបាយផ្សេងៗស្របច្បាប់។
- បង្រៀនពីសារនយោបាយផ្ទាល់របស់គណបក្ស ក្នុងការស្វែងរកការគាំទ្រ។
- គណបក្សសម-រង្ស៊ីមានចលនាស្ត្រី ដោយមានលោកជំទាវ មួរ សុខហួរ ជាប្រធានចលនាស្ត្រី។ នៅរៀងរាល់៣ខែម្តង បានអញ្ជើញស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការកណ្តាលចូលរួមប្រជុំ ដោយបានលើកយកបញ្ហាជាក់ស្តែងនៅតាមមូលដ្ឋាន និងរកនូវដំណោះស្រាយ។

លោកជំទាវក៏មានយោបល់បន្ថែមទៀតថា គោលនយោបាយ ឬផែនការសកម្មភាពរបស់គណបក្សនីមួយៗវាមិនគ្រប់គ្រាន់ទេក្នុងការបង្កើនស្ត្រីឱ្យមានតួនាទីក្នុងនយោបាយ គឺរដ្ឋាភិបាលមានតួនាទីដ៏សំខាន់ក្នុងការចូលរួមលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ។ ដូច្នេះ គណបក្សសម-រង្ស៊ីសូមអំពាវនាវដល់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជួយយកចិត្តទុកដាក់ឧបត្ថម្ភគាំពារ ផ្តល់ចំណេះដឹង ផ្តល់សិទ្ធិពិតប្រាកដ ដើម្បីឱ្យស្ត្រីខ្មែរមានទឹកចិត្ត មានសមត្ថភាពពេញលេញក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិ។

**លោកស្រី ឡាក់ សុភាព** អនុប្រធានចលនាស្ត្រីមកពីគណបក្សសិទ្ធិមនុស្ស បានបង្ហាញថា គណបក្សសិទ្ធិមនុស្សប្រកាន់យកនយោបាយអហឹង្សាដោយប្រកាន់នូវគោលការណ៍យុត្តិធម៌សង្គម ការលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងសកម្មភាពនយោបាយ និងក្នុងសកម្មភាពអភិវឌ្ឍន៍សង្គម ។ ការនិយាយចង់ឱ្យស្ត្រីចូលរួមឱ្យបាន

ច្រើនគឺងាយនិយាយ ប៉ុន្តែការអនុវត្តជាក់ស្តែងវិញពិតជាចម្រូងចម្រាស់ខ្លាំងណាស់ដែលតម្រូវឱ្យយើងរួមគ្នាដោះស្រាយប្រកបដោយសុទិដ្ឋិនិយម សុឆន្ទៈពិតប្រាកដ និងស្រួចស្រាវបំផុត ដោយយើងត្រូវបង្កើនការយល់ដឹងពីបទពិសោធនៃការអនុវត្តគោលនយោបាយយេនឌ័រពីប្រទេសផ្សេងៗ និងជម្រុញឱ្យមានយុទ្ធនាការ ស្តីពី ការបង្កើតគោលនយោបាយយេនឌ័រសម្រាប់គណបក្ស និងក្រុមប្រឹក្សាឃុំ សង្កាត់ ។ លោកស្រីបន្ថែមទៀតថា ច្បាប់បោះឆ្នោតចាប់ពីថ្នាក់ជាតិ ដល់ ឃុំ សង្កាត់ត្រូវកែលំអដើម្បីដាក់បេក្ខជនស្ត្រីស្ថិតក្នុងលំដាប់លេខរៀងដែលអាចជាប់ឆ្នោតបាន ។

**លោកជំទាវ ម៉ែន ម៉ាលី** ប្រធានចលនាស្ត្រីមកពីគណបក្សហ៊្វុនស៊ិនប៉ិច បានមានប្រសាសន៍បង្ហាញពីសមភាពយេនឌ័រមានតាំងពីកំនើតកំណើតគណបក្សហ៊្វុនស៊ិនប៉ិចមកម្ល៉េះ ។ ការលើកកំពស់តួនាទីស្ត្រីក្នុងវិស័យនយោបាយគណបក្សហ៊្វុនស៊ិនប៉ិចបានឈានមុខក្នុងការលើកកំពស់ស្ត្រី ។ សិក្ខាសាលាថ្ងៃនេះពិតជាមានសារៈសំខាន់យើងធ្វើការពិភាក្សា ចែករំលែកនូវបទពិសោធន៍ទៅវិញទៅមកធ្វើយ៉ាងណាដើម្បីឱ្យស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ ជាពិសេសកាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ដូច្នេះគោលនយោបាយរបស់គណបក្សហ៊្វុនស៊ិនប៉ិចបាន និងបន្តការលើកស្ទួយរួចមកហើយនូវគុណតំលៃរបស់ស្ត្រីដែលមិនត្រឹមតែបោះឆ្នោតក្នុងថ្នាក់ក្រោមជាតិទេ សូម្បីតែថ្នាក់ជាតិក៏គណបក្សមានគោលការណ៍ប្រាកដប្រជាផងដែរ ។ ប៉ុន្តែទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ បញ្ហាគន្លឹះជាឧបសគ្គសំរាប់ស្ត្រីនៅតែមានដូចជា ខ្វះការចូលរួម និងជំរុញលើកទឹកចិត្តពីគ្រួសារ បញ្ហាសេដ្ឋកិច្ចក៏ជាបញ្ហាចំបង បញ្ហាសុវត្ថិភាពជាបញ្ហាគួរឱ្យពិចារណាពីគ្រប់មជ្ឈដ្ឋានទាំងអស់ ។

**លោកស្រី មុំ ផល្លា** ប្រធានចលនាស្ត្រី និងជាប្រធានក្រុមការងារស្ត្រីបក្សប្រចាំខេត្តពោធិសាត់មកពីគណបក្សជាតិនិយម( អតីតគណបក្សនរោត្តមរណឫទ្ធិ) បានកោតសរសើរដល់អង្គការខុមហ្វ្រែលដែលរៀបចំសិក្ខា-សាលានេះឡើង វាពិតជាផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ស្ត្រីដែលបានបំរើការក្នុងវិស័យនយោបាយ ដូចជាបង្កើនការយល់ដឹងអំពីបទពិសោធនៃការអនុវត្តគោលនយោបាយយេនឌ័រពីបណ្តាប្រទេសនានា និងជម្រុញឱ្យមានយុទ្ធនាការសំដៅបង្កើតឱ្យមានគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ ដើម្បីផ្តល់ឱកាសឱ្យស្ត្រីខ្មែរកាន់តែចូលរួមសកម្មថែមទៀតក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ។

ទោះបីមិនមានចែងច្បាស់ថាជាគោលនយោបាយយេនឌ័រ ឬការកំណត់កូតាសម្រាប់ស្ត្រីក្នុងកំរិតដឹកនាំជាន់ខ្ពស់ក៏ដោយ នៅក្នុងគោលនយោបាយគណបក្សជាតិនិយម បានធានាប្រសិទ្ធភាព និងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី និងសិទ្ធិកុមារ និងសិទ្ធិជនជាតិដើមភាគតិច/ជនជាតិភាគតិច លើកទឹកចិត្តស្ត្រីឱ្យចូលរួមធ្វើសេចក្តីសម្រេចចិត្តដោយស្មើភាពជាមួយបុរសនៅក្នុងគ្រប់វិស័យសង្គម វប្បធម៌ និងនយោបាយ ។ លោកស្រីបានបន្ថែមថា គណបក្សជាតិនិយមសូមសំដែងនូវការគាំទ្រចំពោះយន្តការតាក់តែងឱ្យមានគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។

**លោកស្រី រស់ សុភាព** នាយិកាអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) បានបង្ហាញអំពីបទពិសោធនៃការបង្កើតគោលនយោបាយយេនឌ័រដោយផ្តោតលើចំណុចសំខាន់ៗដូចជា សមាជិកក្រុមប្រឹក្សានាយកការគ្រប់គ្រងថ្នាក់ប្រធានអង្គការ ការគ្រប់គ្រងថ្នាក់កណ្តាល បុគ្គលិកដែលមិនមែនជាអ្នកគ្រប់គ្រង ប្បេវត្សរ៍ស្មើគ្នា ការធ្វើសេចក្តីសម្រេច ការកសាងសមត្ថភាព ការចូលរួមរបស់សហគមន៍នៅក្នុងគម្រោង។ លោកស្រីបានបញ្ជាក់បន្ថែមអំពី :

**(១) ឧបសគ្គ ឬកត្តារារាំងការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅកម្ពុជានៅក្នុងរចនាសម្ព័ន្ធផ្ទៃក្នុងរបស់គណបក្សនយោបាយៈ**

- មិនមានចំនួនស្ត្រីជាសមាជិកគ្រប់គ្រាន់នៅក្នុងគណបក្សនយោបាយនៅគ្រប់កម្រិត (តាំងពីសមាជិកភាពថ្នាក់ក្រោមដល់ថ្នាក់កណ្តាល)។
- បុរសនៅក្នុងគណបក្សនៅតែប្រកាន់បទដ្ឋានយេនឌ័របុរាណ និងយល់ឃើញថា "*នយោបាយ គឺជាការងារបុរស*"។
- សមត្ថភាពរបស់ស្ត្រី និងជំនឿជឿជាក់លើខ្លួនឯងក្នុងការចូលរួមសកម្មក្នុងកិច្ចការនយោបាយនៅតែជា*បញ្ហា* ពីព្រោះស្ត្រីយល់ថា ការងារនយោបាយគ្រោះថ្នាក់ និងមិនមែនជាការងាររបស់ស្ត្រីទេ។
- បេក្ខជនឈរឈ្មោះបោះឆ្នោតៈ ចំនួនបេក្ខជនស្ត្រីតិចជាងបេក្ខជនបុរស ពីព្រោះគណបក្សនយោបាយគិតថា អ្នកបោះឆ្នោតបុរស អ្នកបោះឆ្នោតស្ត្រីនឹងមិនបោះឆ្នោតឱ្យបេក្ខជនស្ត្រី។
- បេក្ខជនស្ត្រីត្រូវបានដាក់ឱ្យឈរឈ្មោះនៅលេខរៀងខាងក្រោមនៃបញ្ជីឈរឈ្មោះគណបក្ស
- បេក្ខជនស្ត្រីទទួលបានការផ្សព្វផ្សាយ និងគាំទ្រតិចពីសំណាក់អ្នកសារព័ត៌មានក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត។
- ទោះបីស្ត្រីទទួលបានតួនាទីធំនៅជួររាជរដ្ឋាភិបាល ក៏ស្ត្រីនោះមិនទទួលបានការចាត់តាំងឱ្យគ្រប់គ្រងស្ថាប័នធំៗដែរ ដូចជា ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស ។ល។
- តំណាងស្ត្រីជាប់ឆ្នោតនៅថ្នាក់ឃុំ សង្កាត់តិចតួចណាស់ដែលទទួលបានតួនាទីជាមេឃុំ ចៅសង្កាត់។

**(២) សារៈប្រយោជន៍បេក្ខភាពស្ត្រីជាអ្នកនយោបាយ**

- ស្ត្រីយល់ពីតម្រូវការរបស់ស្ត្រី
- ស្ត្រីមានការយល់ឃើញ និងយុទ្ធសាស្ត្រមួយចំនួនដែលមានប្រសិទ្ធភាពខុសពីបុរស។
- បេក្ខភាពស្ត្រីជាអ្នកនយោបាយបង្ហាញពីឆន្ទៈ និងលទ្ធផលពិតប្រាកដរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបបញ្ហាវិសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា។
- បេក្ខភាពស្ត្រី ជាក្តីសង្ឃឹមពិតប្រាកដរបស់ស្ត្រីរងគ្រោះពីអំពើហឹង្សាក្នុងគ្រួសារ និងស្ត្រីជាជនរងគ្រោះពីការរំលោភបំពាន និងជម្រុញការអនុវត្តច្បាប់អំពើហិង្សាក្នុងគ្រួសារ និងអំពើហឹង្សាលើស្ត្រីឱ្យកាន់តែមានប្រសិទ្ធភាព។

- បេក្ខភាពស្ត្រីនឹងបង្កើនប្រជាប្រិយភាពរបស់គណបក្សនយោបាយ ។

**<u>លទ្ធផលក្រុមពិភាក្សា</u>**

| **ក្រុមប្រឹក្សាឃុំ/សង្កាត់ រកឃើញលទ្ធផល** | |
|---|---|
| **❀ មូលហេតុដែលនាំឱ្យមានគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រ:**<br>- ដើម្បីមានការគាំទ្រពីគណបក្សនយោបាយឱ្យមានបុរស និងស្ត្រីស្មើគ្នា ។<br>- ងាយស្រួលក្នុងការសហការអភិវឌ្ឍន៍មូលដ្ឋាន<br>- ដើម្បីទាមទារតម្រូវការមូលដ្ឋាន<br>- ជួយលើកកម្ពស់ដល់ស្ត្រីទៅលើការចូលរួមបញ្ចេញមតិ និងការសម្រេចចិត្ត ។<br>- ជួយដោះស្រាយបញ្ហារបស់ស្ត្រី និងកុមារ<br>- ជួយស្ត្រីឱ្យចេះរៀបចំផែនការ | **❀ យើងអាចបង្កើតគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈ**<br>- ការបណ្តុះបណ្តាលស្ត្រីឱ្យចេះធ្វើផែនការសកម្មភាព<br>- ការបញ្ចូលបញ្ហារបស់ស្ត្រី និងកុមារនៅក្នុងឃុំ<br>- ប្រមូលព័តិមានពីមូលដ្ឋានដើម្បីស្វែងរកតម្រូវការរបស់ស្ត្រី និងបុរសក្នុងការបង្កើតគម្រោង ។<br>- ដាក់បញ្ចូលព័តិមានដែលទទួលបានពីមូលដ្ឋានទៅក្នុងផែនការអនុវត្តន៏គម្រោងប្រចាំឆ្នាំ ។<br>-តាមដានការអនុវត្តន៏គម្រោង ផែនការសកម្មភាពឃុំ សង្កាត់<br><br>**❀ គោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រគួរមានចំណុចសំខាន់៦ដូចខាងក្រោម:**<br>១- ត្រូវមានតម្លាភាព<br>២- ត្រូវមានសមភាព និងសមធម៌យេនឌ័រពិតប្រាកដ<br>៣- ត្រូវមានគណនេយ្យភាព<br>៤- មានការត្រួតពិនិត្យ តាមដាន<br>៥- ផ្តល់ឱកាសដល់ស្ត្រីបានចូលរួមគ្រប់សកម្មភាព<br>៦- បង្កើនសមត្ថភាពដល់ស្ត្រីជាពិសេស |

| **គណបក្សនយោបាយ រកឃើញលទ្ធផល** | |
|---|---|
| **❀ មូលហេតុដែលនាំឱ្យមានគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រ:**<br>- ដើម្បីឱ្យមានចំនួនស្ត្រីចូលរួមក្នុងឆាកនយោបាយឱ្យបានច្រើន ។<br>- ដើម្បីជួយស្ត្រីទទួលបានឱកាសច្រើនក្នុងការឈរឈ្មោះជាបេក្ខជនតាមលំដាប់លេខរៀងឆ្លាស់ ។ | **❀ យើងអាចបង្កើតគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រ សម្រាប់គណបក្សនយោបាយ:**<br>- បណ្តុះបណ្តាលគ្រូបង្គោលពីគណបក្ស អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ។<br>- មានកញ្ចប់ថវិកាសម្រាប់ការឃោសនាដល់បេក្ខជនស្ត្រី<br>- បង្រៀនពីសារនយោបាយ |

| | |
|---|---|
| - ដើម្បីឱ្យមានសមភាពរវាងបុរស និងស្ត្រី ដើម្បីឆ្លើយតបទៅនឹងគោលការណ៍សង្គមជាតិ និងអន្តរជាតិដែលកំពុងតែធ្វើចលនាលើកកម្ពស់ស្ត្រី។ ដូចនេះគណបក្សនយោបាយត្រូវបង្កើតគោលនយោបាយយេនឌ័រ។<br>- ស្ត្រីចូលរួមក្នុងការដឹកនាំច្រើនអាចកាត់បន្ថយភាពក្រីក្រ អំពើហិង្សា និងអំពើពុករលួយ។<br>- ការតស៊ូមតិជាមួយថ្នាក់ជាតិ និងថ្នាក់ដឹកនាំជាន់ខ្ពស់ (ប្រធាន និងអគ្គលេខាធិការ) ដើម្បីបញ្ចូលស្ត្រីក្នុងកម្មវិធីគោលនយោបាយរបស់គណបក្ស ដូចជាលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងឱ្យបានច្បាស់លាស់។<br>- ផ្តល់ឱកាសឱ្យស្ត្រីបានក្លាយជាអ្នកដឹកនាំគណបក្សពីថ្នាក់កំពូលដល់ថ្នាក់មូលដ្ឋាន។<br>- ពង្រឹងសមត្ថភាពស្ត្រី(វិស័យនយោបាយ ការទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋ)។ | - ត្រូវពិនិត្យមើលរចនាសម្ព័ន្ធរបស់គណបក្សនីមួយៗ ហើយបញ្ចូលស្ត្រីជាអ្នកដឹកនាំក្នុងគណបក្ស ចាប់ពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។<br>❀ **គោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រគួរមានចំណុចសំខាន់ៗដូចខាងក្រោមៈ**<br>- យុត្តិធម៌សម្រាប់ស្ត្រី<br>- ផែនការសកម្មភាពក្នុងការបណ្តុះបណ្តាលស្ត្រី<br>- កំណត់ចំនួនកូតាស្ត្រីតាមស្ថាប័ននានារបស់គណបក្ស<br>- ការពារ និងលើកស្ទួយដើម្បីពង្រីកការចូលរួមរបស់ស្ត្រី<br>- ផ្តល់ឱកាសឱ្យស្ត្រីបានក្លាយជាថ្នាក់ដឹកនាំឱ្យបានច្រើន<br>-ត្រូវពិនិត្យមើលរចនាសម្ព័ន្ធរបស់គណបក្សនីមួយៗ ហើយបញ្ចូលស្ត្រីជាអ្នកដឹកនាំក្នុងគណបក្សចាប់ពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។ |

**លោកស្រីធីតា ឃឹះ** នាយិកាអង្គការសីលការ និងអគ្គលេខាធិការ**CPWP** បានថ្លែងក្នុងការសរុបលទ្ធផលនៃអង្គសិក្ខាសាលាទាំងមូលថា គណបក្សនយោបាយទាំង៥ រួមទាំងតំណាងមកពីនាយកដ្ឋានគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងអង្គការសង្គមស៊ីវិល ទទួលស្គាល់ និងគាំទ្រការផ្តល់សិទ្ធិអំណាចនយោបាយដល់ស្ត្រី និងការបង្កើតឱ្យមានគោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ពិតជាមានសារៈសំខាន់ណាស់។ លោកស្រីក៏បានបង្ហាញថា គោលនយោបាយរៀបចំបានលុះត្រាតែថ្នាក់ដឹកនាំគណបក្សនយោបាយទាំងអស់ជឿជាក់ថា ការផ្តល់ឱកាសឱ្យស្ត្រីចូលរួម និងការឱ្យមានវិធានការបណ្តោះអាសន្នដើម្បីផ្តល់អំណាចនយោបាយដល់ស្ត្រីជាការចាំបាច់។ *ជំនឿទី១* ភាពចាំបាច់ដែលត្រូវផ្តល់សិទ្ធិអំណាច ភាពអង់អាចដល់ស្ត្រីគឺដើម្បីយុត្តិធម៌ លទ្ធិប្រជាធិបតេយ្យ និងប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ *ជំនឿទី២* ការផ្តល់សិទ្ធិអំណាច និងឱកាសដល់ស្ត្រីចូលរួមដើម្បីផលប្រយោជន៍រួម។ មានន័យថា ផលប្រយោជន៍មិនមែនបានទៅលើតែស្ត្រី និងកុមារទេ គឺបានទទួលទាំងអស់គ្នារួមទាំងបុរសផងដែរ។ *ជំនឿទី៣* ស្ត្រីទទួលការរើសអើងជាយូរណាស់មកហើយនៅក្នុងសង្គមកម្ពុជា ក្នុងវប្បធម៌ស្ត្រីត្រូវបានលើកស្ទួយខ្លាំង ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានភាពខ្វះចន្លោះច្រើន ដូច្នេះយើងត្រូវការដោះស្រាយបញ្ហានេះ។ *ជំនឿទី៤* យើងត្រូវមានវិធានការពិសេសដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរពីស្ថានភាពខ្សោយរបស់ស្ត្រីក្នុងសង្គម ក្នុងគ្រួសារទៅជាមានឱកាសឈានចូលរួមក្នុងគណបក្សនយោបាយ និងវិស័យនយោបាយ។ កម្ពុជាបានទទួលយកនូវអនុសញ្ញាស៊ី-ដការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងចាត់វិធានការបណ្តោះអាសន្ន ដើម្បីធ្វើឱ្យស្ត្រីបានទទួលនូវភាពយុត្តិធម៌

ការអនុវត្តប្រជាធិបតេយ្យ និងឱ្យមានការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដែលជាមធ្យោបាយគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដូច្នេះបើយើងខ្វះជំនឿខាងលើនេះ តាមការសិក្សាស្រាវជ្រាវទូទាំងពិភពលោក គណបក្សនយោបាយណាដែលមានការយល់ស៊ីជំរៅអំពីបញ្ហាទាំងនេះមិនមែនតែស្ត្រីទេ បុរសផងដែរដែលត្រូវយល់ថា ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី គឺជាការផ្តល់សិទ្ធិអំណាចដល់ខ្លួនឯង។ ដូច្នេះគោលនយោបាយយេនឌ័រជាគោលនយោបាយចាំបាច់ដើម្បីឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើងខាងលើ ការងារជម្រុញឱ្យមានស្ត្រីពុំមែនជាការងាររបស់ស្ត្រីទេ គឺជាការងាររបស់យើងទាំងអស់គ្នាទាំងបុរស ទាំងស្ត្រីដែលជាអ្នកមានតួនាទីនៅក្នុងសង្គម និងក្នុងគណបក្សសំខាន់ណាស់ពីព្រោះគណបក្សនយោបាយជាអ្នកកាន់អំណាច គាត់មានតួនាទី និងកាតព្វកិច្ចក្នុងការដោះស្រាយបញ្ហាសង្គម ។

## សេចក្តីសន្និដ្ឋាន និងលទ្ធផល

តាមរយៈបទបង្ហាញ កិច្ចពិភាក្សា និងពិភាក្សាតាមក្រុមរយៈពេល១ថ្ងៃពេញនេះ បានរកឃើញថា មានការទទួលយក និងគាំទ្រយ៉ាងពេញទំហឹងពីគណបក្សនយោបាយទាំង៥ ក្រុមប្រឹក្សាឃុំ សង្កាត់ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការបង្កើតឱ្យមាន " ***ផែនការសកម្មភាព ឬគោល-នយោបាយយេនឌ័រនៅក្នុងគណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់*** " ដើម្បីលើកស្ទួយសមភាពយេនឌ័រក្នុងកិច្ចការនយោបាយ និងសង្គម ពិសេសលើកទឹកចិត្ត និងផ្តល់អំណាចនយោបាយដល់ស្ត្រីក្នុងការចូលរួមលើគ្រប់វិស័យ។ គោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រគួរមានចំណុចសំខាន់ៗដូចខាងក្រោម:

**គណបក្សនយោបាយ**

- ត្រូវមានយុត្តិធមិសម្រាប់ស្ត្រី
- បង្កើតផែនការសកម្មភាពក្នុងការបណ្តុះបណ្តាលស្ត្រី
- កំណត់ចំនួនកូតាស្ត្រីតាមស្ថាប័ននានារបស់គណបក្សនយោបាយ
- ការពារ និងលើកស្ទួយដើម្បីពង្រីកការចូលរួមរបស់ស្ត្រី
- ផ្តល់ឱកាសឱ្យស្ត្រីបានក្លាយជាថ្នាក់ដឹកនាំឱ្យបានច្រើន
- ត្រូវពិនិត្យមើលរចនាសម្ព័ន្ធរបស់គណបក្សនីមួយៗ ហើយបញ្ចូលស្ត្រីជាអ្នកដឹកនាំក្នុងគណបក្សចាប់ពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។

**ក្រុមប្រឹក្សាឃុំ សង្កាត់**

- ត្រូវមានតម្លាភាព
- ត្រូវមានសមភាព និងសមធម៌យេនឌ័រពិតប្រាកដ
- ត្រូវមានគណនេយ្យភាព
- មានការត្រួតពិនិត្យតាមដាន

- ផ្តល់ឱកាសដល់ស្ត្រីបានចូលរួមគ្រប់សកម្មភាព
- បង្កើនសមត្ថភាពដល់ស្ត្រីជាពិសេស

ការប្តេជ្ញាចិត្ត និងគាំទ្រក្នុងការផ្តល់អំណាចនយោបាយដល់ស្ត្រី និងបង្កើតឱ្យមានគោលនយោបាយយេនឌ័រ សម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ វាមានតម្លៃ និងពិតជាមានសារៈប្រយោជន៍ណាស់ដល់អភិក្រមប្រជាធិបតេយ្យ ជាពិសេសការចូលរួមដោយស្មើភាពរវាងស្ត្រី និងបុរស។ ទោះជាយ៉ាងនេះក៏ដោយ ត្រូវការចាំបាច់បន្ថែមទៀតនូវឆន្ទៈខ្ពស់របស់គណបក្សនយោបាយ (អ្នកដឹកនាំគណបក្ស) និងស្ថាប័នពាក់ពន្ធ័ក្នុងការធ្វើសកម្មភាព និងអនុវត្តគោលនយោបាយយេនឌ័រប្រកបដោយប្រសិទ្ធភាព និរន្តរភាព ប្រយោជន៍លើកទឹកចិត្ត និងផ្តល់ឱកាសទូលាយដល់ការចូលរួមរបស់ស្ត្រីជាអតិបរមាក្នុងវិស័យនយោបាយ និងកិច្ចការសង្គម។

## ឧបសម្ពន្ធ័ទី១

## គំរូនៃផែនការសកម្មភាពសម្រាប់សមភាពយេនឌ័រនៅក្នុងគណបក្សពលករន័រវេស្សន៍

គណបក្សពលករន័រវេស្សន៍មានចក្ខុវិស័យ និងគោលដៅដែលខ្លួននឹងក្លាយជាគណបក្សដែលមានសកម្មភាពជាងគេ។

ផែនការសកម្មភាពសម្រាប់សមភាពយេនឌ័ររបស់គណបក្ស គឺជាឧបករណ៍ការងារមួយដែលពិពណ៌នា អំពីរបៀបដែលយើងនឹងធ្វើការងារដើម្បីសម្រេចបានចក្ខុវិស័យ និងគោលដៅនេះ។

កាអេប់រំ និងការបណ្តុះបណ្តាល គឺជាគន្លឹះមួយឆ្ពោះទៅកាន់ការសម្រេចបានគោលដៅរបស់យើង។ ចំណុចនេះមានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាពនេះ។ ការកសាងសមត្ថភាពផ្តល់នូវចំណេះដឹង និងភាពជឿជាក់ដែលជាកត្តាសំខាន់ដើម្បីមានសកម្មភាពរស់រវើកក្នុងនយោបាយ ទទួលមុខតំណែងជាអ្នកដឹកនាំ និងត្រូវបានគេយកចិត្តទុកដាក់ក្នុងនយោបាយ។

សមាជក្នុង ឆ្នាំ២០០៥បានអនុម័តដូចខាងក្រោម:

" *គណបក្សពលករន័រវេស្សន៍នឹងក្លាយជាគណបក្សដែលមានសមភាពជាងគេ។ គណបក្សនឹងក្លាយជាកំលាំងចលករសម្រាប់សង្គមដែលមានសមភាព។ សមាជនេះជឿជាក់ថាតុល្យភាពយេនឌ័រក្នុងមុខតំណែងធំៗគឺជាបញ្ហាមួយទាក់ទងនឹងវប្បធម៌ ឆន្ទៈ និងសមត្ថភាពក្នុងការបញ្ចប់ប្រពៃណីដែលបុរសគឺជាអ្នកដឹកនាំ។ វាត្រូវការការពារជាប្រព័ន្ធមួយដើម្បីផ្លាស់ប្តូរឥរិយាបថ វប្បធម៌ និងដំណើរការជ្រើសរើស។ គណបក្សត្រូវទទួលខុសត្រូវចំពោះការផ្លាស់ប្តូរការងារ។ សមាជនេះនឹងជំរុញឱ្យស្ថាប័នគណបក្សទទួលខុសត្រូវចំពោះការបង្កើត និងអនុវត្តយុទ្ធសាស្ត្រសមភាព*"។

ដើម្បីក្លាយជាគណបក្សដែលមានសមភាពជាងគេ យើងត្រូវតែធ្វើការជាប្រពន្ធ័ និងដោយមានគោលបំណងច្បាស់លាស់។ យើងត្រូវតែធ្វើការក្នុងគ្រប់លំដាប់ថ្នាក់នៃស្ថាប័នរបស់យើង ក្រុមមូលដ្ឋាន គណបក្សក្រុង

(municipal parties) គណបក្សតំបន់ និងគណបក្សកណ្តាល។ ការធ្វើការងាររួមគ្នាធ្វើឱ្យយើងចាប់ផ្តើមដឹងអំពីឥរិយាបថរបស់យើង យើងជ្រើសរើសអប់រំ រៀបចំបញ្ហានយោបាយសំខាន់ៗ អំពីរបៀបវារៈសមភាពយេឌ័រ និងអនុញ្ញាតិឱ្យស្ត្រីបានចូលរួម។ ស្ថាប័ននៃគណបក្សពលករន័រវែស្សន៍ដែលផ្អែកលើគោលការណ៍សមាហារណកម្ម គឺជាទីភ្នាក់ងារបញ្ញាបរបស់គណបក្សទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលមានការទទួលខុសត្រូវចំពោះសមភាពក្នុងសមភាពរបស់គណបក្ស រដ្ឋាភិបាលមជ្ឈឹមទទួលខុសត្រូវចំពោះការសម្រេចបានគោលបំណងនៃគណបក្សដែលមានសមភាព។

បញ្ហាប្រឈមគឺមានច្រើនជាងនេះ។ គណបក្សមានសមាជិកជាង៥០ ០០០នាក់ ដែល ៤០%នៃសមាជិកទាំងអស់គឺជាស្ត្រី។ យើងក៏មានចំនួនលើសលុបនៃបុរសដែលជាអ្នកដឹកនាំក្នុងស្ថាប័នគណបក្សផងដែរ និងមានស្ត្រីតែ ២៩%ប៉ុណ្ណោះរបស់គណបក្សដែលជាចៅហ្វាយក្រុង។ យើងក៏ដឹងដែរថា បុរសច្រើនជាងស្ត្រីឈរឈ្មោះបោះឆ្នោតឡើងវិញក្នុងក្រុមប្រឹក្សាក្រុង (municipal boards) ។

ការប្តេជ្ញាចិត្តជាវិជ្ជមានអំពីស្ត្រី៥០% និងបុរស៥០%ក្នុងគ្រប់ការិយាល័យ និងមុខតំណែងទាំងអស់ក្នុងគណបក្សគឺបង្ហាញអំពីឆន្ទៈដើម្បីទទួលបានសមភាពពិតប្រាកដ។ គណបក្សជឿជាក់ថា ស្ត្រីក៏អាចដឹកនាំដូចបុរសដែរ។ ដូច្នេះវាជារឿងយុត្តិធម៌ និងសមហេតុផលក្នុងការដែលមានចំនួនបុរស៥០% និងស្ត្រី៥០%ជាអ្នកដឹកនាំក្នុងគណបក្ស។

ដើម្បីទទួលបានស្ត្រីបន្ថែមក្នុងមុខតំណែងដឹកនាំ គណៈកម្មាធិការកណ្តាល គណបក្សនយោបាយក្រុងធំ (county parties) គណបក្សក្រុង (municipal parties) ចាំបាច់ត្រូវអនុលោមតាមការជ្រើសរើស និងការតែងតាំងរបស់គណបក្ស។ ស្ត្រីត្រូវបានគេស្នើជាលក្ខណៈប្រព័ន្ធដើម្បីទទួលបានមុខតំណែង ដូច្នេះយើងបានប្រើប្រាស់ជំនាញនៃសមាជិករបស់យើងតាមវិធីល្អបំផុតដែលអាចធ្វើទៅបាន។ វាជាការទទួលខុសត្រូវរៀងៗខ្លួនរបស់គណបក្សក្រុង (municipal and county parties) ដើម្បីធានាថា លក្ខន្តិកៈទាក់ទងនឹងតុល្យភាពយេនឌ័រត្រូវបានគេគោរពតាម។

ការអប់រំ និងការបណ្តុះបណ្តាល គឺជាគន្លឹះមួយឆ្ពោះទៅកាន់ការសម្រេចបានគោលដៅរបស់យើង ។ ចំណុចនេះមានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាពនេះ។ ការកសាងសមត្ថភាពផ្តល់នូវចំណេះដឹង និងភាពជឿជាក់ដែលជាកត្តាសំខាន់ដើម្បីមានសកម្មភាពរស់រវើកក្នុងនយោបាយ ទទួលមុខតំណែងជាអ្នកដឹកនាំ និងត្រូវបានគេយកចិត្តទុកដាក់ក្នុងនយោបាយ។

យើងជំរុញឱ្យគណបក្សក្រុង (municipal and county parties) បង្កើតផែនការសកម្មភាពសម្រាប់សមភាពយេនឌ័រ ដើម្បីឱ្យស្ថាប័នទាំងមូលអាចធ្វើការរួមគ្នា ដើម្បីឱ្យមានសមភាពក្នុងគណបក្ស។

## ១. តួនាទីបណ្តាញស្ត្រី

ការរៀបចំឡើងវិញនៃចលនាស្ត្រី និងការងារសមភាពយេនឌ័ររបស់គណបក្សត្រូវបានធ្វើឡើងនៅសមាជក្នុងឆ្នាំ២០០៥ ដើម្បីឱ្យមានការផ្លាស់ប្តូររបៀបធ្វើការងារ។ បណ្តាញក្នុងស្ថាប័នគណបក្សមានតួនាទីខុសពីការងារអង្គការឯករាជ្យ។

គោលការណ៍ណែនាំសម្រាប់គណបក្សពលករន័រវេស្សន៍ គឺជាគោលបំណងរបស់បណ្តាញស្រ្តី:

" បណ្តាញស្រ្តីនឹងក្លាយជាកម្លាំងចលករមួយ ដើម្បីដាក់បញ្ហានយោបាយរបស់ស្រ្តីនៅក្នុងរបៀបវារៈ (បណ្តាញស្រ្តីក្នុងការជ្រើសរើស អប់រំ និងលើកទឹកចិត្តស្រ្តីទាំងអស់របស់គណបក្សក្នុងការងារនយោបាយ ជាពិសេសក្នុងមុខតំណែងដឹកនាំ) ។ ស្រ្តីទាំងអស់ក្នុងគណបក្សនឹងត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងបណ្តាញស្រ្តី "។

បណ្តាញស្រ្តីនឹងក្លាយជាឱកាសមួយសម្រាប់ស្រ្តីទាំងអស់នៅក្នុងគណបក្ស ហើយបណ្តាញនេះនឹងលុបបំបាត់គម្លាត ព្រមទាំងភាពខុសគ្នានៅពេលដែលសមាជិកគណបក្សក្លាយជាអ្នកតំណាង និងជាបណ្តាញជ្រើសរើសសំរាប់សមាជិកស្រ្តី។

AUF មាននារីដែលមានទេពកោសល្យដែលស្ថាបន័គណបក្សចង់ធ្វើការជាមួយ។ បណ្តាញស្រ្តីនឹងសហការជាមួយAUF ទាំងខាងសកម្មភាព ទាំងខាងនយោបាយ។

បណ្តាញនេះត្រូវតែបើកចំហជាកន្លែងបំពេញបន្ថែម លើកទឹកចិត្ត និងពិភាក្សាអំពីនយោបាយ។

ស្ថាប័នបណ្តាញគណបក្ស គឺជាទម្រង់ស្ថាប័នរស់រវើកមួយដែលផ្តល់ឱ្យគណបក្សក្រុង (municipal and county parties) នូវសេរីភាពទាក់ទងនឹងរបៀបរៀបចំការងារ និងបណ្តាញរបស់ពួកគេ។

បណ្តាញនេះនឹងផ្តោតលើការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ពីព្រោះខ្លួនគឺជាអ្នកផ្តល់ចំណេះដឹង និងភាពជឿជាក់។ បណ្តាញស្រ្តីនឹងក្លាយជាកំលាំងចលករមួយក្នុងការសាកល្បងទម្រង់ថ្មីៗនៃការជួបជុំក្នុងគណបក្ស។ វប្បធម៌នៃការជួបជុំគួរតែកំណត់ដោយការបើកចំហរ និងការចូលរួម។ គ្រប់កិច្ចប្រជុំទាំងអស់របស់គណបក្សគួរតែមានម៉ោងចាប់ផ្តើម និងម៉ោងបញ្ចប់។ គណបក្សទំនើបត្រូវតែបំពេញទម្រង់ទាំងនេះ។ វប្បធម៌របស់សមាជិកអាចរួមចំណែកតាមរយៈសមត្ថភាព និងឆន្ទៈ ព្រមទាំងការប្រើប្រាស់ពេលវេលាសមស្រប។

ច្បាប់របស់គណបក្សក៏ផ្តល់នូវគោលការណ៍ណែនាំសម្រាប់បណ្តាញស្រី និងការងាររបស់ខ្លួនក្នុងគណបក្សផងដែរ។ គោលបំណង ការរៀបចំសេដ្ឋកិច្ច និងការទទួលខុសត្រូវនៅគ្រប់ថ្នាក់ទាំងអស់នៃគណបក្ស គឺ មានពិពណ៌នានៅទីនេះ។ នៅថ្នាក់ក្រុង (county level) ព្រមទាំងថ្នាក់កណ្តាល ទទួលខុសត្រូវផ្នែករដ្ឋបាល ចំពោះការងារក្នុងបណ្តាញស្រ្តី តាមរយៈថវិកា និងធនធានរដ្ឋបាលផ្ទាល់ខ្លួនរបស់ពួកគេ។

## ២. ឧបករណ៍

**គណបក្សក្រុង (Municipal Parties)**

គណបក្សក្រុង គឺជាចំណុចកណ្តាលឆ្ពោះទៅសមភាពយេនឌ័រ។ គ្រប់គណបក្សក្រុងទាំងអស់គួរតែបង្កើតផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់សមភាពយេនឌ័រ ហើយបញ្ជូនទៅគណបក្សនយោបាយក្រុងធំ (county parties) នៅជំណាច់ចុងខែឧសភា។ ក្រុមប្រឹក្សាគួរតែទទួលខុសត្រូវចំពោះសមភាពយេនឌ័រនៅក្នុងរបាយការណ៍ប្រចាំឆ្នាំទៅលើគន្លឹះសំខាន់របស់ផែនការសកម្មភាពដែលផ្តោតលើសមភាព។

**គណបក្សក្រុងធំ(County parties)** មានការទទួលខុសត្រូវលើហិរញ្ញវត្ថុ និងរដ្ឋបាលសម្រាប់ការងារសមភាពរបស់ គណបក្សក្រុង (Municipal parties)។ វគ្គបណ្តុះបណ្តាលមានសារៈសំខាន់ ដើម្បីទទួលបាននូវ

៥០/៥០។ "*ការផ្តោតចំពោះស្ត្រី*" គឺ ការផ្តល់នូវការយកចិត្តទុកដាក់ និងការអប់រំយ៉ាងល្អដែលmunicipal parties គួរតែរៀបចំយ៉ាងតិចឱ្យបាន១ដងក្នុង១ឆ្នាំ។ តើវាសមស្របដែរឬទេដែល municipal parties ធ្វើការរួមគ្នាដើម្បីផ្តល់វគ្គបណ្តុះបណ្តាលនៅតាមតំបន់ និងសកម្មភាពផ្សេង។

**គណបក្សក្រុង (Municipal Parties):**

- រៀបចំពេលវេលាសំរាប់វគ្គបណ្តុះបណ្តាល និងគម្រោងនៅមូលដ្ឋានសម្រាប់សមភាពយេនឌ័រ។
- អ្នកទទួលខុសត្រូវសម្រាប់ការសម្របសម្រួលសកម្មភាព ដូចនេះគ្រប់គ្នាអាចចូលរួមនៅក្នុងគណបក្ស
- ប្រធានក្រុមប្រឹក្សាមូលដ្ឋានទទួលខុសត្រូវសម្រាប់ការរៀបចំការប្រជុំ និងរបៀបវារៈ ព្រមទាំងស្នើការអង្កេតលើរដ្ឋបាល ថាតើមានលក្ខណៈល្អសមស្របទៅនឹងយុទ្ធសាស្ត្រការងារដើម្បីឱ្យស្ត្រី និងបុរសមានលក្ខណៈងាយស្រួលក្នុងការចូលរួមនៅក្នុងអង្គភាពដែលត្រូវបានគេបោះឆ្នោតដែរឬទេ។
- បង្កើតឱ្យមានអាសយដ្ឋានទំនាក់ទំនងរវាងអាសយដ្ឋាបេក្ខនារីនៅក្នុងក្រុម និងសមាជិកស្ត្រីនៅក្នុងគណបក្សក្រុង។
- ជូនដំណឹងដល់គណៈកម្មាធិការបោះឆ្នោត/គណៈកម្មាធិការតែងតាំងរដ្ឋធម្មនុញ្ញ គណបក្សនឹងស្នើគណៈកម្មាធិការស្វែងរកបេក្ខភាពស្ត្រី នៅក្នុងមុខតំណែងថ្នាក់ដឹកនាំដែលស្ត្រីមិនមានកន្លែង។

**គណបក្សផ្សេងទៀត (NA Parties)**

County Party មានការទទួលខុសត្រូវជាចំបងសម្រាប់បណ្តាញស្ត្រីនៅក្នុង County ។ County party អាចបង្កើតបណ្តាញនៅថ្នាក់តំបន់ជាកន្លែងដែលពួកគេយល់ថាចាំបាច់ និងមានលក្ខណៈសមស្រប។ គណបក្សផ្សេងទៀតក៏មានតួនាទីសំខាន់នៅក្នុងសកម្មភាពនៅក្នុង county និងរៀបចំផែនការសកម្មភាពសម្រាប់សមភាពយេនឌ័រ និងបកស្រាយលើសមភាពយេនឌ័រក្នុងរបាយការណ៍ប្រចាំឆ្នាំ។ County party ក៏មានការទទួលខុសត្រូវលើហិរញ្ញវត្ថុ និងរដ្ឋបាលលើបណ្តាញស្ត្រីផងដែរ។

គ្រប់ស្ត្រីនៅក្នុងគណបក្សពលករនឹងទទួលបានវគ្គបណ្តុះបណ្តាល ហើយCounty party មានតួនាទីដោយឡែកនៅក្នុងការតាមដាន។

**គណបក្សក្រុងធំ (COUNTY PARTY):**

- បង្កើត អនុវត្ត និងការវាយតំលៃវគ្គបណ្តុះបណ្តាលនៅក្នុងកិច្ចសហការជាមួយ Municipal Parties
- បន្ថែមសម្របសម្រួលការបណ្តុះបណ្តាលសម្រាប់សមាជិកស្ត្រី អ្នកតំណាងដែលត្រូវជ្រើសរើសឱ្យគេបោះឆ្នោតឱ្យ និងអ្នកតាក់តែងច្បាប់។
- ធានាក្នុងការបង្កើតបណ្តាញសារអេឡិចត្រូនិច ( e-mail ) និងភ្ជាប់សារអេឡិចត្រូនិចរបស់សមាជិក
- រៀបចំសន្និសីទសម្រាប់ស្ត្រីនៅក្នុង County ដើម្បីលើកកម្ពស់គោលនយោបាយ ជំរុញសមភាព និងធ្វើឱ្យគណបក្សទទួលបានភាពស្មើភាព។
- បង្រួបបង្រួមក្រុមប្រឹក្សា County ដើម្បីទទួលខុសត្រូវការបង្កើតទម្រង់អង្គប្រជុំលើរបៀបវារៈ ព្រមទាំងស្នើ

អង្កេតលើរដ្ឋបាលថាតើមានលក្ខណៈល្អសមស្របទៅនឹងយុទ្ធសាស្ត្រការងារដើម្បីឱ្យស្ត្រី និងបុរសមានលក្ខណៈងាយស្រួលក្នុងការចូលរួមនៅក្នុងអង្គភាពដែលត្រូវបានគេបោះឆ្នោតដែរឬទេ។

- បណ្តាញស្ត្រីនៅក្នុង County ត្រូវជំរុញការបង្កើតឱ្យបណ្តាញអ្នកតំណាង។ គោលបំណងគឺដើម្បីលើកទឹកចិត្តឱ្យអ្នកតំណាងដែលត្រូវឱ្យគេបោះឆ្នោត និងបង្កើតកន្លែងប្រជុំដើម្បីពិភាក្សាលើបញ្ហានយោបាយ និងការផ្លាស់ប្តូរបទពិសោធ។
- ការប្រើ ការបង្កើតបណ្តាញ និងបង្កើតយុត្តាធិការនៅក្នុងគណបក្សនៅក្នុងមូលដ្ឋាន ដើម្បីជះឥទ្ធិពល និងបង្កើតរបៀបវារៈ។

### ក្រុមដឹកនាំ

ក្រុមដឹកនាំបណ្តាញស្ត្រីនឹងជាកម្លាំងនៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បអនុវត្តការប្រជុំសម្រេចចិត្តរបស់ County។ ក្រុមដឹកនាំនឹងពង្រាង និងអនុវត្តផែនការសកម្មភាពសម្រាប់សមភាពយេនឌ័រ និងរដ្ឋាភិបាលកណ្តាលដើម្បីទទួលខុសត្រូវចំពោះសមភាពយេនឌ័រនៅក្នុងរបាយការណ៍ទៅកាន់សមាជ។ ក្រុមដឹកនាំមានសារៈសំខាន់នៅក្នុងសកម្មភាពផែនការ និងកិច្ចសហប្រតិបត្តិការដើម្បីលើកទឹកចិត្ត និងចូលរួមផ្តល់នូវបណ្តាញល្អ និងប្រកបដោយការអនុវត្តនៅក្នុង County និងការចែងរំលែកបទពិសោធពីស្ថាប័ន។

សមាជិកគណបក្សពលករមាននូវធនធានដែលមានលក្ខណៈរឹងមាំទាំងនៅក្នុង និងក្រៅគណបក្ស។ ទាំងនេះនឹងផ្តល់ឱ្យគណបក្សនេះអាចរៀនសូត្រ ទំនាក់ទំនង និងបង្កើតភាពជិតស្និទ្ធរវាងគ្នាទៅវិញទៅមក។ ដូចនេះយើងនឹងបង្កើតផែនការបង្ហាត់បង្រៀន ការត្រួតពិនិត្យ ការណែនាំបន្ថែមទៀត។ ស្ត្រីដែលមានបទពិសោធនៅក្នុងគណបក្សដែលមានភាពសកម្ម គឺជាមូដែលគំរូ ឬអ្នកណែនាំដើម្បីលើកទឹតចិត្ត និងចែករំលែកបទពិសោធ។ *តើយើងអាចថែរក្សាស្ត្រីដែលមានមុខងារសំខាន់ដែលជាទំនុកចិត្តសំរាប់គណបក្ស និងប្រើប្រាស់បទពិសោធ និងចំណេះដឹងពួកគេយ៉ាងដូចម្តេច ?*

ការជ្រើសរើសការអនុវត្តស្ត្រីដែលនៅថ្នាក់លើត្រូវបានតែងតាំងជាអចិន្ត្រៃយ៍ និងបង្កើតឡើងសម្រាប់ County ទាំងអស់។

បណ្តាញស្ត្រីភ្ជាប់និងគណបក្សនយោបាយនឹងបើកផ្លូវ ដើម្បីបញ្ចូលនូវបញ្ហានយោបាយរបស់ស្ត្រីនៅក្នុងរបៀបវារៈ ។នៅក្នុងឆ្នាំ២០០៨/២០០៩ បណ្តាញស្ត្រីនឹងធ្វើការជាក់លាក់លើៈ

- ទទួលបាននូវការបង់ថ្លៃស្មើគ្នាទាំងថ្នាក់មូលដ្ឋាន និងថ្នាក់កណ្តាល
- ការគំរាមគំហែង ការបៀតបៀនកេរ្តិ៍ខ្មាស់
- អំពើហិង្សាក្នុងគ្រួសារ
- Heldagskolen
- ដើម្បីទទួលបាននូវអនុសញ្ញាស្តីពី "**ស្ត្រី**" របស់អង្គការសហប្រជាជាតិបញ្ចូលទៅក្នុងច្បាប់របស់ប្រទេសន័រវេស្សន៍។

**ក្រុមដឹកនាំ និងការិយាល័យគណបក្សគួរតែៈ**

- បង្កើតកម្មវិធីបណ្តុះបណ្តាលដែលជំរុញឱ្យមានសមភាពយេនឌ័រ និងចំណេះដឹងផ្នែកស្ថាប័ន និងការដឹកនាំ។
- ការអនុវត្តស្ត្រីថ្នាក់ដឹកនាំនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយ County Party
- បណ្តាញស្ត្រីគ្រូបង្គោល ការផ្តោតលើស្ត្រី
- បង្កើតសន្និសីទជាតិ Gere សិក្ខាសាលា វេទិកាពាក់ព័ន្ធលើបញ្ហាស្ត្រី
- ការចូលរួមសកម្មភាពនៅក្នុងកម្មវិធីពិភាក្សា
- បន្តការត្រួតពិនិត្យ/កម្មវិធីសម្រាប់ស្ត្រីនៅក្នុងគណបក្ស។ មូលដ្ឋានបទពិសោធន៍របស់សមាជិកបណ្តាញស្ត្រីនៅក្នុងស្ត្រីជាអ្នកដឹកនាំ។
- ផ្តល់ព័ត៌មានលើកិច្ចប្រឹងប្រែង នឹងភាពជោគជ័យតាមរយៈសមាជិកវិបផត www.dna.no
- ធ្វើការងារភ្ជាប់ស្ត្រីដែលមានចំនួនតិច និងជំរុញការប្រឈមរបស់ពួកគេនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាមួយប្រទេសផ្សេងៗទៀត។
- បង្កើត និងផ្តល់ព័ត៌មាន ស្តីពី តារាងបង្ហាញសមភាពយេនឌ័រសម្រាប់ប្រធាន និងគណបក្ស
- បង្កើតឱ្យមាននូវការទទួលឪជីធីវដែលស្ថាបន័អាចចែករំលែកនូវការចំណាយស្មើភាព
- កៀរគរថ្នាក់ដឹកនាំនៅក្នុងបណ្តាញស្ត្រីយ៉ាងតិចឱ្យបាន១ដងក្នុង១ឆ្នាំ
- តាមដានលើស្ត្រីដែលមានមុខងារជាចៅហ្វាយក្រុង ឬចៅហ្វាយក្រុងរង
- កៀរគរសមាជិកដែលជាថ្នាក់ដឹកនាំស្ត្រីនៅ County ដែលដឹកនាំការប្រជុំ គណៈកម្មាធិការប្រតិបត្តិដើម្បីពិនិត្យមើលឡើងវិញនូវបញ្ហាបច្ចុប្បន្ន។
- ធ្វើការស្ទង់មតិលើចំនួនស្ត្រីដែលលាលែងពីរដ្ឋធម្មនុញនៅក្នុង counties and municipalities
- បង្កើនការយល់ដឹងស្តីពី ចំណេះដឹង ការបៀតបៀនកេរ្តិ៍ខ្មាស់នៅក្នុងគណបក្ស។

## ឧបសម្ព័ន្ធទី២
## សកម្មភាព និងលទ្ធផលនៃកម្មវិធីស្ត្រីអាចធ្វើបាន

បច្ចុប្បន្ន សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួនបានចូលរួមគាំទ្រការបង្កើតបណ្តាញស្ត្រី សមាគមជួយខ្លួនឯងក្នុងកិច្ចការងារស្ត្រី និងកុមារ ព្រមទាំងមានកម្មវិធីក្នុងការជំរុញ ពង្រឹងសមត្ថភាព និងផ្តល់ឱកាសឱ្យស្ត្រីបានចូលរួមយ៉ាងទូលំទូលាយក្នុងវិស័យនយោបាយ និងគាំទ្រឱ្យស្ត្រីមានសិទ្ធិបញ្ចេញមតិក្នុងការអភិវឌ្ឍន៍សង្គមជាតិ និងសិទ្ធិឈរឈ្មោះបោះឆ្នោត។ ដោយឡែកខុមហ្វ្រែលបានធ្វើសកម្មភាពលើគំរោងមួយចំនួនដែលពាក់ព័ន្ធនឹងស្ត្រី ដូចជា គំរោងស្តីពី *"ស្ត្រីអាចធ្វើបាន និងការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត"* ដើម្បីចូលរួមពង្រឹងអំណាចស្ត្រី ដែលជាក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ខណ្ឌ មេភូមិ អនុភូមិ សមាជិកភូមិ

មន្ត្រីមូលដ្ឋាន សកម្មជនគណបក្សនយោបាយ សកម្មជនអង្គការក្រៅរដ្ឋាភិបាល និងលើកទឹកចិត្តស្ត្រីឱ្យចូលរួមកាន់តែច្រើនថែមទៀតទៅលើការកសាងទំនុកចិត្ត ផ្តល់នូវការរៀនសូត្រអំពីរិធាននៃការងារនយោបាយ និងផ្តល់នូវភាពអង់អាចក្លាហានដល់ស្ត្រីដើម្បីបញ្ចេញមតិ និងចូលរួមក្នុងដំណើរការសំរេចចិត្ត។ ចាប់ពីពាក់កណ្តាល ឆ្នាំ២០០៨ គំរោងនេះបានធ្វើសកម្មភាពនៅខេត្តចំនួន៣ គឺ ខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ធំ និងចាប់ពីឆ្នាំ២០០៩រហូតដល់បច្ចុប្បន្ន ខុមហ្វ្រែលបានពង្រីកតំបន់គោលដៅរបស់ខ្លួនចំនួន**៥ខេត្ត** គឺ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តព្រះវិហារ ដោយបានធ្វើសកម្មភាពចំនួន**៣០ស្រុក**។ តាមរយៈគំរោងនេះ ខុមហ្វ្រែលបានធ្វើការបណ្តុះបណ្តាលចំនួន**៣០វគ្គដល់ស្ត្រី** ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានសមាសភាពមកពីគណបក្សនយោបាយដែលមានអាសនៈនៅក្នុងសភា និងក្រុមប្រឹក្សា ឃុំ សង្កាត់ ភ្នាក់ងារ/ សកម្មជនគណបក្សនយោបាយ ប៉ូលីសមូលដ្ឋាន មេភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីកិច្ចការនារី ស្រុក ឃុំ អភិបាលរងស្រុក គ្រូបង្រៀន សកម្មជន/បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល សរុបចំនួន**៩០១នាក់** ស្មើនឹង **១០០%ជាស្ត្រី** និងចងក្រងបណ្តាញស្ត្រីបានចំនួន **១០៤នាក់** ដែលមកពីគណបក្សប្រជាជនចំនួន**៥៩នាក់** គណបក្សសមរង្ស៊ីចំនួន**១៩នាក់** គណបក្សនរោត្តមរណឫទ្ធិចំនួន**០២នាក់** គណបក្សហ៊្វុនស៊ិនប៉ិចចំនួន**០៦នាក់** គណបក្សសិទ្ធិមនុស្សចំនួន**០១នាក់** មន្ត្រីមូលដ្ឋានចំនួន **០៨នាក់** បុគ្គលិកអង្គការ និងសកម្មជនខុមហ្វ្រែលចំនួន **០៩នាក់** ប្រយោជន៍ឱ្យបណ្តាញស្ត្រីទាំងនោះធ្វើសកម្មភាពនៅតាមភូមិ ឃុំរបស់ខ្លួន ដូចជា ផ្តល់ការយល់ដឹងដល់ប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋជាស្ត្រីតាមរយៈការអប់រំផ្សព្វផ្សាយឯកសារអប់រំខុមហ្វ្រែល ចូលរួម និងពិភាក្សាក្នុងវេទិកាសាធារណៈស្ត្រី តាមដាន និងឃ្លាំមើលអំពីស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ លើកឡើងនូវបញ្ហាស្ត្រី និងកុមារទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងជំរុញឱ្យមានការដោះស្រាយ ។ល។ និង ។ល។ លើសពីនេះទៀត ខុមហ្វ្រែលបានរៀបចំជាវេទិកាសាធារណៈ ស្តីពី "ស្ត្រីអាចធ្វើបាន" ដើម្បីពិភាក្សា និងរកដំណោះស្រាយបញ្ហាស្ត្រី និងកុមារបានចំនួន**១៥លើក** មានអ្នកចូលរួមសរុបចំនួន**៩០៤នាក់** ក្នុងនោះមានស្ត្រីចំនួន**៦៤៧នាក់** ស្មើនឹង **៧១,៥៧%** ។

ជាលទ្ធផលយោងតាមការសិក្សាស្រាវជ្រាវរបស់ខុមហ្វ្រែលឆ្នាំ២០១០ បង្ហាញថា **៧៨,២%**នៃស្ត្រីដែលទទួលបានការបណ្តុះបណ្តាលឆ្លើយថា ពួកគាត់មានការជំរុញឱ្យមានការដោះស្រាយបញ្ហាស្ត្រី និងកុមារ លើកទឹកចិត្ត និងអប់រំ ផ្សព្វផ្សាយឱ្យស្ត្រីចេះសំអាតខ្លួន ឱ្យស្ត្រីទៅមណ្ឌលសុខភាព ឱ្យកុមារចូលរៀន សិទ្ធិស្ត្រី តួនាទីស្ត្រី ជំរុញឱ្យមេភូមិ និងគណៈកម្មការ សមាគមភូមិជួយដោះស្រាយជំលោះប្តីប្រពន្ធ និងគណបក្សរបស់ខ្លួនផងដែរ។ តួយ៉ាង លោកស្រី **ខៀវ ផន** នៅភូមិអង្គត្នោតខាងកើត ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិច បានលើកឡើងថា "កាលពីថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០១០ ពេលប្រជុំនៅគណបក្ស អង្គប្រជុំមិនបានលើកពីបញ្ហាស្ត្រី និងកុមារទេ ខ្ញុំក៏បានទាមទារឱ្យគេលើកបញ្ហាស្ត្រី និងកុមារជារបៀបវារៈ អង្គប្រជុំយល់ព្រមឱ្យដាក់បញ្ហានេះបញ្ចូលក្នុងរបៀបវារៈ"។ ឥឡូវនេះ ខ្ញុំបានបង្កើតបណ្តាញស្ត្រីគណបក្សនយោបាយចំនួន ៨ភូមិ នៅក្នុងឃុំរបស់ខ្ញុំ។

**៩៤.៤%**នៃស្ត្រីដែលទទួលបានការបណ្តុះបណ្តាល និយាយថា " បន្ទាប់ពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្ត្រីអាចធ្វើបាន ការងាររបស់ពួកគាត់មានភាពល្អប្រសើរជាងមុន។ ពួកគាត់ធ្វើការដោយជឿជាក់លើខ្លួនឯង។ នៅក្នុងអង្គប្រជុំពួកគាត់អាចជជែកពិភាក្សា និងដឹងពីមធ្យោបាយដោះស្រាយបញ្ហា "។ ជាក់ស្តែងកញ្ញា **ស៊ីន សាមឿន** អាយុ ៣៨ឆ្នាំ រស់នៅភូមិខ្លាក្របីមក ឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ មានតួនាទីជាមន្ត្រីកិច្ចការនារីស្រុកកោះអណ្តែត ជាសមាជិកគណបក្សប្រជាជនកម្ពុជា។ កញ្ញាធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលកម្មវិធីស្ត្រីអាចធ្វើបាន និងការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសំរេចចិត្ត កាលពីថ្ងៃទី១៦-១៨ ខែតុលា ឆ្នាំ២០០៩ កញ្ញាបានមានប្រសាសន៍ថា "ពីមុនខ្ញុំអៀនច្រើន និងមិនសូវហ៊ាននិយាយឬក៏បញ្ចេញមតិនៅកន្លែងធ្វើការទេ ក្រោយពីបានរៀនវគ្គនេះមក ខ្ញុំមានសេចក្តីក្លាហានជាងមុន ហើយការងាររបស់ខ្ញុំក៏មានភាពប្រសើរជាងមុនដែរ"។ គាត់បន្តទៀតថា " វគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ណាស់ព្រោះបានផ្តល់ចំណេះដឹងថ្មី ឯកសារ ជាពិសេសបានបង្កើនភាពក្លាហានដល់ខ្ញុំ "។ កញ្ញាបានយកចំណេះដឹងនេះទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមសហគមន៍របស់គាត់ តាមរយៈការប្រជុំភូមិ ការប្រជុំក្រុមប្រឹក្សាឃុំ ជាពិសេសនៅកន្លែងធ្វើការរបស់គាត់។ គាត់និយាយបន្តទៀតថា " ឥឡូវបុរសនៅកន្លែងធ្វើការរបស់ខ្ញុំចាប់ផ្តើមគាំទ្រខ្ញុំ ហើយសរសើរថាស្ត្រីឥឡូវក្លាហាន និងចេះបង្រៀនស្ត្រីៗគ្នាឯង "។ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ខ្ញុំបានផ្សព្វផ្សាយចំណេះដឹងនេះ និងឯកសារអប់រំ ដូចជា សៀវភៅរូបភាព ស្ទីកឃ័រ និងសៀវភៅសំណួរ-ចំលើយរបស់ខុមហ្វ្រែលនៅកម្មវិធីផ្សព្វផ្សាយសុខភាពបន្តពូជ និងអំពើហឹង្សាក្នុងគ្រួសារនៅក្នុងឃុំក្រពុំឈូក។ មេរៀនដែលខ្ញុំផ្សព្វផ្សាយគឺយេនឌ័រ ការតស៊ូមតិ និងបំផុសសេចក្តីក្លាហានក្នុងការធ្វើសេចក្តីចិត្តក្នុងកិច្ចការសង្គម និងឈរឈ្មោះបោះឆ្នោត។

ឥឡូវនេះ ស្ត្រីៗដែលបានចូលរួមវគ្គផ្សព្វផ្សាយរបស់ខ្ញុំ ហ៊ានឈរឈ្មោះបោះឆ្នោតជាបណ្តាញស្ត្រីភូមិ និងជាតំណាងក្រុមស្ត្រី (អ្នកកាន់ប្រាក់សន្សំក្នុងភូមិ)។ សព្វថ្ងៃខ្ញុំមានក្រុមស្ត្រីនៅក្នុងភូមិខ្លាក្របីមករ ឃុំក្រពុំឈូក ពីរក្រុម (មួយក្រុមបង្កើតដោយខ្លួនផ្ទាល់) ហើយទាំងពីរក្រុមនេះមានសមាជិកចំនួន ៥០នាក់ (ក្នុងនោះមានប្រុស ៨នាក់)។ ពួកគាត់មានតួនាទីសន្សំប្រាក់ សន្សំស្រូវ និងដាំដំណាំ ដើម្បីបង្វិលជួយស្ត្រីក្នុងភូមិ ហើយនៅពេលស្ត្រី និងកុមារក្នុងភូមិដែលជួបការលំបាក ឈឺថ្កាត់ អាចប្រើប្រាស់ប្រាក់សន្សំនេះបាន។ មិនតែប៉ុណ្ណោះបណ្តាញស្ត្រីរបស់ខ្ញុំមានភារកិច្ចជាអ្នកកាន់ប្រាក់សន្សំ ដោះស្រាយបញ្ហាស្ត្រី និងកុមារ និងផ្សព្វផ្សាយយេនឌ័រក្នុងភូមិ។ គាត់បន្តទៀតថា សព្វថ្ងៃខ្ញុំមានបញ្ហាលំបាកខ្លះដោយសារឆ្នាំនេះក្តៅខ្លាំង ក្រុមស្ត្រីរបស់ខ្ញុំប្រមូលផលស្រូវសន្សំមិនបានច្រើន។ ពិសេសជាងនេះពេលខ្ញុំហៅស្រីៗក្នុងភូមិប្រជុំម្តងៗ ពួកគាត់មិនសូវចូលរួម ជួនកាលចូលរួមមិនចប់ចុងចប់ដើម ។ គាត់និយាយថា " ខ្ញុំមានតែឆន្ទៈបើកការប្រជុំ ប៉ុន្តែមិនមានថវិកាទិញអាហារសំរន់សម្រាប់ការប្រជុំ ដូច្នេះខ្ញុំមានការពិបាកខ្លាំងក្នុងការហៅគាត់មកប្រជុំ ម្យ៉ាងទៀតស្រីៗក្នុងភូមិគាត់គិតពីការងារផ្ទះច្រើនជាង "។ នៅឆ្នាំ២០១០ គាត់មានបំណងចងបណ្តាញស្ត្រីរបស់គាត់ផ្ទាល់ក្នុងភូមិខ្លាក្របីមក ឃុំក្រពុំឈូក ដើម្បីសន្សំប្រាក់ សន្សំស្រូវ ដាំដំណាំ និងផ្សព្វផ្សាយយេនឌ័រ និង អំពើហឹង្សាលើស្ត្រី និងកុមារដល់ស្ត្រី-បុរសនៅក្នុងភូមិរបស់គាត់ឱ្យបានគ្រប់គ្នា។

## ឧបសម្ពន្ធ័ទី៣

## បញ្ជីវត្តមានអ្នកចូលរួមសិក្ខាសាលា ស្តីពី "ការផ្តល់អំណាចនយោបាយដល់ស្ត្រី និង គោលនយោបាយយេនឌ័រសម្រាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់"

| តំណាងគណបក្សនយោបាយ | តំណាងស្ថាប័ន និងអង្គការជាតិ អន្តរជាតិ | តំណាងសារព័ត៌មាន | | |
|---|---|---|---|---|
| | | កាសែតក្នុងស្រុក | ស្ថានីយ៍ទូរទស្សន៍ | វិទ្យុ |
| ▪ ប្រជាជនកម្ពុជា<br>▪ សម រង្ស៊ី<br>▪ សិទ្ធិមនុស្ស<br>▪ ហ្វ៊ុនស៊ីនប៉ិច<br>▪ ជាតិនិយម | ▪ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ<br>▪ AMARA<br>▪ Committee to Promote Women in Politics(CPWP)<br>▪ Cambodia Women for Peace and Development (CWPD)<br>▪ Cambodia Development Research Institute (CDRI)<br>▪ EU<br>▪ Forum Syd<br>▪ Gender and Development for Cambodia (GAD/C)<br>▪ GIZ-PWR<br>▪ Khmer Youth Association (KYA)<br>▪ NGO-CEDAW<br>▪ Oxfam Novib<br>▪ PDP<br>▪ UNIFEM<br>▪ UNDP/SDEP<br>▪ Women for Prosperity (WfP)<br>▪ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា<br>▪ សមាជិករាជរដ្ឋាភិបាល<br>▪ សមាជិកសភា/តំណាងរាស្ត្រ<br>▪ ក្រសួងកិច្ចការនារី<br>▪ ក្រុមប្រឹក្សាឃុំ/សង្កាត់<br>▪ សម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំ សង្កាត់<br>▪ បណ្តាញស្ត្រីខុមប្រែ្រល | ▪ កោះសន្តិភាព<br>▪ រស្មីកម្ពុជា<br>▪ កាសែតចិន ជាន ហ្វា<br>▪ កាសែតចិនយ៉ាវ៉ាន់ប៉ាវ<br>▪ កាសែតចិន ស៊ីនជីន ដេលី<br>▪ ភ្នំពេញប្រេស<br>▪ ភ្នំពេញប៉ុស្តិ៍ | ▪ ទូរទស្សន៍ CTN<br>▪ ទូរទស្សន៍ប៉ុស្តិ៍លេខ៩ (CTV9)<br>▪ ទូរទស្សន៍បាយ័ន | ▪ វិទ្យុស្ត្រី FM ១០២ MHz<br>▪ វិទ្យុជាតិកម្ពុជា FM ១០៥.៧៥ MHz<br>▪ វិទ្យុ FM ៩៦ MHz<br>▪ វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) |

## ឧបសម្ពន្ធ័ទី៤

## ការចុះ និងចាក់ផ្សាយរបស់ប្រពន្ធ័ផ្សព្វផ្សាយ

សិក្ខាសាលានេះត្រូវបានចុះផ្សាយតាមទំព័រកាសែតចំនួន**៥**នៅក្នុងស្រុកគឺ កាសែតកោះសន្តិភាព រស្មីកម្ពុជា កាសែតចិន ជាន ហ្វា កាសែតជិនយ៉ាវ៉ាន់ប៉ាវ និងកាសែតចិន ស៊ីនជីន ដេលី និងចាក់ផ្សាយតាមស្ថានីយ៍ទូរទស្សន៍ចំនួន**៣** គឺទូរទស្សន៍ CTN ទូរទស្សន៍ប៉ុស្តិ៍លេខ៩ និងទូរទស្សន៍បាយ័ន និងចាក់ផ្សាយតាមវិទ្យុចំនួន**៣** គឺ វិទ្យុស្ត្រី FM១០២ វិទ្យុជាតិកម្ពុជា FM ១០៥.៧៥ MHz និងវិទ្យុFM ៩៦MHz ផងដែរ ។

3 柬埔寨星洲日報
2010年9月15日(星期三)
國內新聞 National

## 政途不平坦

# 鄉民抗拒女性參政

（金边讯）由于女性政治家仍不容易被乡区选民接受，阻碍了我国妇女参政机会。

女性政治活动促进委员会（CWPD）、性别和发展组织（GAD/C）和柬埔寨自由与公正选举委员会（COMFREL），于昨日上午举办“妇女政治权力和性别政策”研讨会，并邀请内政部、人民党、沈良西党等5党代表出席。

柬自由与公正选举委员会（COMFREL）行政主任郭拔亚表示，基于社会文化与历史渊源，加上贫困、无知及歧视，以致女性的政途并不平坦。

他举例，上届全国乡分区理事会选举，各政党候选人当中，女性占了53%，惟最终成功当选的女议员，只占总议员人数的22%。

他说，虽然政府要求各省议会至少拥有23名女议员（白马省除外），区议会则至少有169名女议员，但最终结果还是取决于选民。

郭拔亚表示，根据调查显示，乡分区理事会选举中，女性候选人的得票率和比男性来得低，这主要是因为当地选民对女性候选人的能力和受欢迎程度，存有偏见。另外，女性候选人缺乏资金，也对她们参政构成障碍。



“妇女政治权力和性别政策”研讨会。

他认为，若我国要实现联合国千禧年发展目标，即在2015年实现30%女性参政，我国乡区选民就必须给予女性候选人更全面和公平的待遇。

កោះសន្តិភាព ◆ លេខ 7068 ថ្ងៃ ព្រហស្បតិ៍ ទី 23 ខែ កញ្ញា ឆ្នាំ 2010

ព្រឹត្តិការណ៍សង្គម

# នៅឆ្នាំ2015ប្រទេសកម្ពុជានឹងកំណត់ឱ្យស្ត្រីជាប់ឆ្នោត30ភាគរយ



*ទិដ្ឋភាពទូទៅនៃអង្គសិក្ខាសាលានៅសណ្ឋាគារកាំបូឌីយ៉ាណា (រូបថត អ៊ុយសុង)*

**រាជធានីភ្នំពេញ ៖** ដើម្បីសំរេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស កម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតជាស្ត្រី យ៉ាងហោចណាស់ក៏មាន៣០ភាគរយដែរ ប៉ុន្តែផែនការនេះទំនងជាមិនអាចធ្វើបានទេ ដោយហេតុថា គណបក្សនយោបាយទាំងអស់នៅកម្ពុជាបានលើកហេតុផលដូចគ្នាថា ការដាក់ឈ្មោះបេក្ខភាពជាស្ត្រី គណបក្សរបស់ខ្លួនមានការធ្លាក់ចុះចំនួនសន្លឹកឆ្នោត និងអាសនៈនៅក្នុងរដ្ឋសភា ឬក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់។ ដូច្នេះការដាក់ស្ត្រីនៅក្នុងបញ្ជីបោះឆ្នោតគឺជាការលះបង់។

នេះជាកង្វល់មួយដែលត្រូវបានគេលើកឡើងនៅក្នុងសិក្ខាសាលាស្តីពី ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសំរាប់គណបក្សនយោបាយ និងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលរៀបចំឡើងដោយអង្គការខុមហ្វ្រែលកាលពីថ្ងៃទី១៤ កញ្ញា នៅសណ្ឋាគារកាំបូឌីយ៉ាណា។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងបង្កើនការយល់ដឹងអំពីការផ្តល់អំណាចនយោបាយដល់ស្ត្រី និងសេចក្តីត្រូវការដើម្បីរៀបចំគោលនយោបាយយេនឌ័រសំរាប់គណបក្ស និងក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ។

អង្គសិក្ខាសាលាលើកឡើងថា ជាទំលាប់ការដាក់បញ្ជីបេក្ខជនឈរឈ្មោះគឺផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចជាសមត្ថភាព ប្រជាប្រិយភាព ធនធានថវិកា និងអតីតភាពនៅក្នុងគណបក្សនយោបាយ ។ លក្ខណៈវិនិច្ឆ័យនេះគឺជាឧបសគ្គមួយដ៏ធំសំរាប់បេក្ខនារីដែលមានបំណងឈរឈ្មោះដើម្បីឱ្យគេបោះឆ្នោត។ គណបក្សសំខាន់ៗនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នសុទ្ធតែបានលើកឡើងថា ការលើកស្ទួយយេនឌ័រ ឬការផ្តល់អំណោយនយោបាយខាងយេនឌ័រ(ស្ត្រី)ពិតជាមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណបក្សរួចទៅហើយ ប៉ុន្តែគណបក្សទាំងនោះពុំទាន់មានគោលនយោបាយច្បាស់លាស់ទាក់ទិននឹងយេនឌ័រនៅក្នុងកិច្ចការគណបក្សនៅឡើយទេ។

អង្គសិក្ខាសាលាបានបន្តថា នៅក្នុងប្រទេសកម្ពុជាគណបក្សនយោបាយគឺជាតួអង្គសំខាន់ណាស់ក្នុងការជំរុញឱ្យមានការរីកចំរើនដល់ការផ្តល់អំណាចយេនឌ័រ ពីព្រោះថា ប្រព័ន្ធបោះឆ្នោតនៅកម្ពុជាគឺជាប្រព័ន្ធសមាមាត្រ បញ្ជីបេក្ខជនជារបស់គណបក្សដែលគណបក្សឬថ្នាក់ដឹកនាំគណបក្សជាអ្នកសំរេច៕ ***អ៊ុយសុខ***

# COMFREL：柬政府应加强女性人才培养

时间：2010-9-14 18:09:02

核心提示：本报记者小陈、达拉沃报道

**柬埔寨自由公正选举委员会(COMFREL)今日上午在金宝殿酒店召开论坛，呼吁柬政府加强女性人才培养，以促进柬埔寨男女平等。**据联合国开发计划署2009年在柬埔寨的人类发展指数...




本报记者小陈、达拉沃报道

柬埔寨自由公正选举委员会(COMFREL)今日上午在金宝殿酒店召开论坛，呼吁柬政府加强女性人才培养，以促进柬埔寨男女平等。

据联合国开发计划署2009年在柬埔寨的人类发展指数 ( Human Development Index）指出，柬埔寨的男女平等每年的发展率仅有0.424%，在109个调查国中排名第91名，数据显示柬埔寨在男女平等方面仍有相当差距。

柬埔寨自由公正选举委员会执行主任坤潘亚表示，目前柬埔寨的可投票民众中女性达53%，但女性的议员候选人却没几个，女性领导人也仅有几位，因此柬埔寨应尽快培养各级女性领导人。内政部官员宣称，柬埔寨政府虽然已经让许多女性参与各个政府部门工作，但柬埔寨的确有必要培养女性领导人，尤其是从基层的乡县政府开始，不断提高女性工作参与面、提高女性人才综合领导能力，为优秀的女性人才进入政坛创造条件。

作者：佚名　来源：金边晚报

http://www.jinbianwanbao.com/Html/?1630.html

រស្មីកម្ពុជា

ឆ្នាំទី 18 លេខ 5305 ថ្ងៃ សុក្រ ទី 17 ខែកញ្ញា ឆ្នាំ2010 ០5

# សង្គមស៊ីវិលគណបក្សនយោបាយជំរុញការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្សនិងក្រុមប្រឹក្សាឃុំសង្កាត់

**ភ្នំពេញ :** សង្គមស៊ីវិល និងគណបក្សនយោបាយ បានឯកភាពគ្នានៅក្នុងសិក្ខាសាលាមួយកាលពីថ្ងៃទី១៤កញ្ញា នេះនៅសណ្ឋាគារកំបូឌីយ៉ាណាថា ត្រូវតែជំរុញឱ្យមានការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្ស និងក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលបានកំណត់ថា នៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតជាស្ត្រីមានយ៉ាងតិច៣០ភាគរយ ។

លោកគល់ បញ្ញា នាយកប្រតិបត្តិនៃអង្គការខុមហ្វ្រែល បាននិយាយថា: "បើនិយាយអំពីការផ្តល់អំណាចនយោបាយយេនឌ័រ គឺនិយាយដល់ការពង្រឹងការលើកស្ទួយ និងការការពារការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចចិត្តខាងនយោបាយ រួមទាំងការផ្តល់លទ្ធភាពនិងឱកាសដល់ស្ត្រីដើម្បីទទួលបានអំណាចនយោបាយ" ។

តាមរបាយការណ៍របស់ខុមហ្វ្រែល បានបង្ហាញថា កម្ពុជាមិនទាន់មានសមភាពយេនឌ័រនៃការផ្តល់អំណាចខាងនយោបាយ ពិសេសភាពជាតំណាងអ្នក បោះឆ្នោត ថ្វីបើអ្នកចុះឈ្មោះបោះឆ្នោតជាស្ត្រីមាន៥៣ភាគរយក៏ដោយ គឺស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រមានចំនួនតែ២២ភាគរយ សម្រាប់អាណត្តិទី៤និងស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានចំនួន២០ភាគរយនៅអាណត្តិទី២។

យោងតាមរបាយការណ៍របស់ UNDP Human's Development Index ឆ្នាំ២០០៩ បានបង្ហាញថា កម្ពុជាមានកម្រិតទាបនៃសមធម៌យេនឌ័រនៅក្នុងចំណោមប្រទេសអាស៊ីភាគច្រើន ។ ទោះបីបានទទួលលទ្ធផលរីកចម្រើនខ្លះនៅក្នុងគោលនយោបាយលើកស្ទួយសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ គឺនៅតែប្រឈមច្រើន ហើយកំណែទម្រង់និងការអនុវត្តន៍គោលនយោបាយនៅមានភាពទន់ខ្សោយនៅឡើយ៕

**ទេព មង្គល**



*អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ជំរុញការផ្តល់អំណាចនយោបាយដល់ស្ត្រី និងគោលនយោបាយយេនឌ័រសម្រាប់គណបក្ស និងក្រុមប្រឹក្សាឃុំ សង្កាត់ (រូបថត:វិសាល)*

# 柬公正选举组织召开“两性平等”研讨会

## 冀增加国会女性政党候选人议席



研讨会现场

【本报记者子兴14日报道】柬埔寨自由公正选举组织（COMFREL）与其它非政府组织今日在金宝殿大酒店召开了有关“政党和乡分区理事会妇女政治权力和两性平等政策”研讨会，内政部地方行政部门副主任康如利，人民党、沈良西党、人权党、奉辛比克党和民族主义党等代表应邀出席会议。

柬埔寨自由公正选举组织执行主任关班亚说，虽然柬埔寨在第四届全国选举的投票者中，妇女占53%，但是被选为女议员的只有27人，占约21%，而女性在政府单位的人数是：一位副总理、2位部长、16位国务秘书、30位副国务秘书、23位副省市长、169位副县区长、2270位乡分区理事。无论如何，女性不论在政府单位，包括法制单位的代表还不足，需要有待增加。

关班亚执行主任说，根据该组织的调查发现，各参加选举政党的候选人名单中，很少有女性是候选人，大多数都是男性，主要原因是政党怕输掉选举，但也有其它原因包括风俗习惯等。因此，通过今天的研讨会，相信将能够改变政党对女性没有信心的观念，同时采取措施，加强女性的政治权力。他说，这次论坛的目的是加强女性在政治上的权力，为制订女性平等政策做好准备，以推动各政党制订妇女活动项目和制定两性平等的项目等。

康如利副主任说，内政部地方行政部门已于2002年起，就与相关合作伙伴，包括国内外非政府组织在内密切联系，加强女性在政治领域的权力，增加地方政府乡分区理事会的女理事的人数。

康如利副主任说，王国政府这15年来积极开展推动实现柬埔寨千禧年发展目标的工作，包括通过推动两性平等，政府单位加强女性的权利，增加女国会议员的席位，提高妇女社会地位，同时还要提倡妇女积极参与政治领域。

据了解，第四届国会议席共有123个席位，其中女议员占27个议席，相当于占21%。从1993年至2003年，国会每5年一届的国会议员人数平均增加2%，但2008年的第四届国会议员人数增加了12%。在参议院的63个议席中，女性占了8个席位，相当于占13%，这数据与世界和地区国家相比还比较低。因此，为实现千禧年的目标，政府制订要在2015年前，达到国会女议员占30%（再增长9%），参议院女议员占21%（再增长17%）的目标。